# ការវាយតម្លៃអាជីវកម្មចិញ្ចឹមជ្រូក នៅកម្ពុជា

## សៀវភៅណែនាំស្តីពីការគ្រប់គ្រងហានិភ័យ សម្រាប់ ធនាគារ និង ស្ថាប័នមីក្រូហិរញ្ញវត្ថុ

## ថ្ងៃទី ១០ តុលា ២០០៨

កាលបរិច្ឆេទ : ថ្ងៃទី ១០ តុលា ២០០៨

សៀវភៅនេះ ត្រូវបានរៀបចំឡើងសម្រាប់ការពិនិត្យរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ ។ សៀវភៅនេះ ត្រូវបានចងក្រងឡើងដោយលោក Phil Psilos សម្រាប់គម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម

# កិច្ចសន្យាលេខ GEG-I-00-02-00014-00 លេខរៀងកិច្ចការ O២
# គម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម កម្ពុជា

**សេចក្តីបញ្ជាក់:**
ទស្សនៈរបស់អ្នកនិពន្ធដែលបានបង្ហាញនៅក្នុងរបាយការណ៍ មិនឆ្លុះបញ្ចាំងទស្សនៈរបស់ទីភ្នាក់ងារសហរដ្ឋអាមេរិកសម្រាប់ការអភិវឌ្ឍអន្តរជាតិ ឬទស្សនៈរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ ។

## ការវាយតម្លៃអាជីវកម្មផលិតជ្រូកនៅកម្ពុជា

សៀវភៅណែនាំស្តីពីការគ្រប់គ្រងហានិភ័យសម្រាប់ស្ថាប័នហិរញ្ញវត្ថុកម្ពុជា

### សេចក្តីផ្តើម

ការយល់ដឹងច្រើនអំពីវិស័យឧស្សាហកម្មមួយអាចជួយឱ្យអ្នកប្រកបមុខរបរផ្តល់ប្រាក់កម្ចីធ្វើការវាយតម្លៃបានល្អប្រសើរទៅលើអ្នកខ្ចីប្រាក់ និងកាត់បន្ថយហានិភ័យសម្រាប់ប្រាក់កម្ចីរបស់ស្ថាប័នហិរញ្ញវត្ថុ។ អ្នកប្រកបអាជីពផ្តល់ប្រាក់កម្ចីមិនមែនសុទ្ធតែជាអ្នកជំនាញផ្នែកឧស្សាហកម្មទាំងអស់នោះទេ ហើយអាចនឹងមិនមានលទ្ធភាពក្នុងការទទួលបានព័ត៌មានច្បាស់លាស់អំពីបញ្ហានានា និងលក្ខណៈវិនិច្ឆ័យដែលទាក់ទងនឹងអាជីវកម្មនៅក្នុងវិស័យជាក់លាក់ណាមួយ។ សៀវភៅណែនាំនេះត្រូវបានតាក់តែងឡើងដើម្បីជាជំនួយឆ្លើយតបចំពោះបញ្ហាខាងលើ ។

សៀវភៅនេះផ្តល់ព័ត៌មាន និងមធ្យោបាយសម្រាប់អ្នកផ្តល់ប្រាក់កម្ចី ដើម្បីជួយពួកគេឱ្យស្គាល់អ្នកខ្ចី ដែលគួរអោយទុកចិត្តបាននៅក្នុងឧស្សាហកម្មជ្រូកនៅកម្ពុជា។ ធនាគារ និងស្ថាប័នមីក្រូហិរញ្ញវត្ថុអាចប្រើប្រាស់សៀវភៅណែនាំនេះជាផ្នែកមួយនៃដំណើរការវាយតម្លៃប្រាក់កម្ចី និងគ្រប់គ្រងហានិភ័យ ដើម្បីធានាថា ប្រាក់កម្ចីត្រូវបានផ្តល់ទៅអោយអាជីវកម្មចិញ្ចឹមជ្រូកដែលមានការគ្រប់គ្រងបានល្អ និងប្រកបដោយវិជ្ជាជីវៈ។ គេមិនអាចធានាថា អាជីវកម្មចិញ្ចឹមជ្រូកដែលគ្រប់គ្រងបានល្អ សុទ្ធតែបានចំណេញនោះឡើយ ប៉ុន្តែប្រសិនបើព័ត៌មាននៅក្នុងសៀវភៅនេះត្រូវបានប្រើប្រាស់ដើម្បីបំពេញបន្ថែមទៅលើវិធីគ្រប់គ្រងហានិភ័យផ្សេងៗទៀតរបស់ស្ថាប័នហិរញ្ញវត្ថុ វានឹងផ្តល់ជាមូលដ្ឋានសម្រាប់ការទ្រទ្រង់កំណើនរបស់សហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យម នៅក្នុងវិស័យកសិឧស្សាហកម្មកម្ពុជា ។

សៀវភៅណែនាំនេះត្រូវបានរៀបចំឡើងដោយគម្រោងពង្រឹងសហគ្រាសខ្នាតតូចបំផុត ខ្នាតតូច និងខ្នាតមធ្យមកម្ពុជាដែលឧបត្ថម្ភមូលនិធិដោយសហរដ្ឋអាមេរិកតាមរយៈទីភ្នាក់ងារសហរដ្ឋអាមេរិកដើម្បីអភិវឌ្ឍន៍អន្តរជាតិ និងអនុវត្តដោយ ឌី អេ អាយ (DAI) ។

## រចនាសម្ព័ន្ធនៃឧស្សាហកម្មជ្រូកនៅកម្ពុជា

ការចិញ្ចឹមជ្រូកនៅកម្ពុជាកំពុងស្ថិតក្នុងដំណាក់អន្តរកាលដែលប្រែក្លាយពីសកម្មភាពចិញ្ចឹមលក្ខណៈប្រពៃណីទ្រង់ទ្រាយតូចនៅក្រោយផ្ទះ ទៅជាសកម្មភាពមួយដែលអាជីវកម្មជាច្រើនអនុវត្តនៅក្នុងទ្រង់ទ្រាយធំដើម្បីចូលរួមនៅលើទីផ្សារ។ ដោយសារតែវិស័យនេះងាយនឹងទទួលរងគ្រោះដោយសារការនាំចូលខ្ពស់ ឧស្សាហកម្មជ្រូកនៅកម្ពុជាពុំទាន់មានលក្ខណៈវិជ្ជាជីវៈពេញលេញ ឬឈានដល់កម្រិតដែលចាំបាច់ដើម្បីប្រកួតប្រជែងប្រកបដោយប្រសិទ្ធភាពជាមួយនឹងប្រទេសថៃ និងវៀតណាមនៅឡើយ។ ប៉ុន្តែទោះជាយ៉ាងនេះក្តី ប្រទេសកម្ពុជាមានប្រៀបច្រើនជាងដៃគូប្រកួតប្រជែងនៅក្នុងតំបន់ខាងផ្នែកវត្ថុធាតុដើមចំណីសត្វ - ជាពិសេស ពោត សណ្តែក និងដំឡូង ។ល។ វត្តមាននៃធនធានដែលស្ថិតក្នុងបរិមាណគ្រប់គ្រាន់ដើម្បីទ្រទ្រង់កំណើននៃឧស្សាហកម្មនេះ បាននាំអោយក្រុមហ៊ុនសំខាន់ៗមួយចំនួនរួមមានក្រុមហ៊ុន CP Corporation, Kampot Frams និងក្រុមហ៊ុនថ្មីទៀតរបស់លោកឧកញ៉ា ម៉ុង ឫទ្ធី ដាក់ទុនវិនិយោគទៅលើការលើកកម្ពស់វិស័យនេះតាមរយៈការនាំមកនូវផលិតផលចំណីសត្វថ្មីៗ និងធនធានសំរាប់ការបង្កាត់ពូជជ្រូក។ ក្រុមហ៊ុនផលិតចំណី និងឱសថសត្វក៏ត្រូវបានបង្កើតឡើងដើម្បីបម្រើតម្រូវការទីផ្សារ។

សហគ្រាសខ្នាតតូច និងខ្នាតមធ្យម (SME) នៅជនបទមួយចំនួន ក៏ទំនងជានឹងស្វែងរកឥណទានដើម្បីពង្រីកអាជីវកម្មចិញ្ចឹមជ្រូករបស់ពួកគេផងដែរ ដើម្បីឈានដល់កម្រិតផលិតកម្មមួយ ដែលអនុញ្ញាតអោយពួកគេអាចប្រកួតប្រជែងនៅក្នុងទីផ្សារនៅកម្ពុជាបាន ។ មគ្គុទ្ទេសក៏នេះផ្តល់ព័ត៌មាននិងមធ្យោបាយដល់អ្នកអោយគេខ្ចីប្រាក់ ដើម្បីយល់កាន់តែច្បាស់អំពីអាជីវកម្មរបស់អ្នកចិញ្ចឹមជ្រូក ព្រមទាំងប្រតិបត្តិការផលិតកម្មរបស់ពួកគេ និងវាយតម្លៃប្រតិបត្តិការអាជីវកម្មរបស់ពួកគេទាំងនោះអោយមានប្រសិទ្ធភាពច្រើនជាងមុន ។

### ប្រភេទទាំង ៣ នៃអាជីវកម្មផលិតជ្រូក

ប្រភេទទាំង ៣ នៃសហគ្រាសផលិតជ្រូក គឺបង្កើត និងចិញ្ចឹមខ្លួនឯង (ផលិតកូនជ្រូក និងចិញ្ចឹមវាបំប៉នយកសាច់) បង្កើត និងលក់ទៅអោយអ្នកចិញ្ចឹម (ផលិតកម្មកូនជ្រូក) និងចិញ្ចឹមបំប៉ន និងលក់ជាជ្រូកសាច់ (ចិញ្ចឹមបំប៉នដើម្បីលក់ជាជ្រូកសាច់) ។ ជាទូទៅ ផលិតករជ្រើសរើសគំរូអាជីវកម្មដែលត្រូវគ្នានឹងមុខជំនាញ ធនធាន និងរបៀបរស់នៅរបស់ពួកគេ ។ ចំណុចពិចារណាសំខាន់ៗនៅក្នុងការជ្រើសរើសគំរូអាជីវកម្មផ្នែកចិញ្ចឹមជ្រូក រួមមាន :

- ចំនួនដើមទុន កម្លាំងពលកម្ម និងដីដែលមាន ។
- កម្រិតនៃជំនាញផ្នែកគ្រប់គ្រង និងម៉ាឃីតធីងដែលត្រូវការ ។
- ផលប៉ះពាល់ផ្នែកសង្គម និងបរិស្ថានដែលពាក់ព័ន្ធនឹងការគ្រប់គ្រងលាមកសត្វ ។

### អ្នកចិញ្ចឹមបំប៉នដើម្បីលក់ជាជ្រូកសាច់ (ការចិញ្ចឹមបំប៉នយកសាច់)

សហគ្រាសទិញកូនជ្រូកយកទៅចិញ្ចឹមបំប៉នដើម្បីលក់ជាជ្រូកសាច់ គឺអាជីវកម្មជ្រូកទូទៅជាងគេបំផុតនៅកម្ពុជា ។ ពួកគេទិញកូនជ្រូកទម្ងន់ពី ១២ ទៅ ១៥គីឡូក្រាម យកទៅចិញ្ចឹមបំប៉នអោយធំធាត់បានទម្ងន់ប្រហែល ១០០ គីឡូក្រាម រួចហើយលក់ទៅអោយទីផ្សារ ។ អ្នកពូកែចិញ្ចឹមអាចចិញ្ចឹមជ្រូកសម្រាប់លក់ទៅទីផ្សារក្នុងរយៈពេល ប្រហែលជា ៤ ខែកន្លះ ។ ប្រព័ន្ធនេះអស់ការចំណាយគ្រប់គ្រងទាប ត្រូវការកម្លាំងពលកម្មតិចតួច និងមិនចាំបាច់មានការប្តេជ្ញាចិត្តរយៈពេលវែងផងទេ ។ ប្រតិបត្តិការចិញ្ចឹមជ្រូកបំប៉នដើម្បីលក់ជាជ្រូកសាច់ផ្តល់ឱកាសអោយកសិករដែលដាំដុះធញ្ញជាតិសម្រាប់ប្រើប្រាស់ចំណីសត្វដែលដាំដុះដោយខ្លួនឯងដើម្បីចិញ្ចឹមបំប៉នជ្រូក ដោយមិនចាំបាច់

ត្រូវចាត់ចែងការបង្កាត់ពូជឡើយ ។ ប្រតិបត្តិការនេះក៏អាចប្រមូលប្រាក់ទុនពីតម្លៃជាជីលាមកសត្វបានផងដែរ ។ ចំណុចសំខាន់ដែលគួរយកចិត្តទុកដាក់គិតគូរ គឺប្រភព សុខភាព និងគុណភាព នៅពេលទិញកូនជ្រូកយកមកចិញ្ចឹម ។ ការកាត់បន្ថយចំនួនកសិដ្ឋានដែលផលិតកូនជ្រូកលក់ នឹងជួយកាត់បន្ថយបញ្ហាសុខភាពនៃកូនជ្រូក ។

**ការបង្កើតកូនជ្រូកលក់ទៅអោយអ្នកចិញ្ចឹម (ផលិតកម្មកូនជ្រូក ឬ "កន្លែងបង្កាត់ពូជជ្រូក")**

សហគ្រាសបង្កើតកូនជ្រូកលក់ទៅអោយអ្នកចិញ្ចឹម គឺជាអាជីវកម្មជំនាញ ។ សហគ្រាសបង្កើតកូនជ្រូកលក់ទៅ អោយអ្នកចិញ្ចឹមនេះ គឺទាក់ទងនឹងការចិញ្ចឹមជ្រូកមេបង្កាត់ពូជ និងបង្កើតកូនជ្រូកដើម្បីលក់នៅពេលដែលកូនជ្រូក មានទម្ងន់ពី ១២ ទៅ ១៥ គីឡូក្រាម ទៅអោយអាជីវកម្ម ឬអ្នកចិញ្ចឹមជ្រូកបំប៉នយកសាច់ ។ វាកាត់បន្ថយនូវតម្រូវការគ្រឿងសម្ភារៈ ដើមទុនប្រតិបត្តិការ និងបរិមាណចំណី និងលាមកសត្វដែលត្រូវចាត់ចែង ។ សកម្មភាពនេះក៏ផ្តល់នូវមូលដ្ឋានគ្រឹះសម្រាប់ការបង្កើនចំនួនជ្រូកមេ ឬពង្រីកទៅជាប្រតិបត្តិការបង្កើតកូនជ្រូក និងចិញ្ចឹមបំប៉នដើម្បីលក់ជាជ្រូកសាច់ផងដែរ ។ គុណវិបត្តិធំបំផុតនៃប្រព័ន្ធនេះ គឺថា អ្នកផលិតកូនជ្រូក ជាពិសេសអ្នកដែលមានចំនួនជ្រូកមេតិច គឺស្ថិតនៅក្រោមអំណាចនៃទីផ្សារកូនជ្រូកដែលមានការប្រែប្រួលយ៉ាងរហ័ស ។ សហគ្រាសនេះអាចត្រូវការនូវជ្រូកមេជាច្រើនដែលអាចបង្កើតកូនជ្រូកដើម្បីបង្កើនចំនួនកូនជ្រូកសម្រាប់ការលក់នៅក្នុងអំឡុងពេលដែលតម្រូវការកើនឡើងខ្ពស់ ។

**ការបង្កើតកូនជ្រូក និងចិញ្ចឹមបំប៉នលក់ទៅអោយទីផ្សារ (ផលិតកម្មរួមបញ្ចូលគ្នា)**

ជម្រើសរួមបញ្ចូលគ្នាដែលមានលក្ខណៈវិជ្ជាជីវៈបំផុត គឺ សហគ្រាស***បង្កើតកូនជ្រូក និងចិញ្ចឹមបំប៉នលក់ទៅអោយទីផ្សារ*** ។ សហគ្រាសនេះទាក់ទងនឹងការចិញ្ចឹមជ្រូកមេដើម្បីបង្កាត់ពូជ និងបង្កើតកូន ហើយចិញ្ចឹមបំប៉នកូនជ្រូក រហូតដល់វាមានទម្ងន់ប្រមាណ ១០០ គីឡូក្រាម ។ រយៈពេលនៃផលិតកម្មទាំងមូល គឺពី ១០ ទៅ ១១ខែ ដោយ ក្នុងនោះ ៤ខែសម្រាប់ការបង្កាត់ និងផើម បូកនឹងរយៈពេលប្រហែល ៥ ទៅ ៦ខែ ដើម្បីចិញ្ចឹមកូនជ្រូកអោយធំធាត់ រហូតដល់ទម្ងន់ដែលត្រូវលក់ទៅអោយទីផ្សារ ។ ក្នុងចំណោមប្រព័ន្ធផលិតកម្មជ្រូកទាំងបី ការបង្កើត និងចិញ្ចឹមរួមគ្នានេះ មានសក្តានុពលភាពទីផ្សាររយៈពេលវែង និងភាពបត់បែនច្រើនជាងគេបំផុត ។ ប្រព័ន្ធនេះក៏ទាមទារនូវដើមទុន កម្លាំងពលកម្ម និងមុខជំនាញច្រើនជាងគេបំផុតផងដែរ ហើយថែមទាំងទាមទារអោយមានការប្តេជ្ញាចិត្តរយៈពេលវែងចំពោះអាជីវកម្មចិញ្ចឹមជ្រូកនេះទៀតផង ។

គំរូថវិកាសម្រាប់សហគ្រាសនៅក្នុងប្រភេទនីមួយៗក្នុងចំណោមប្រភេទទាំងនេះ ព្រមទាំងផែនការអាជីវកម្ម និងគំរូបញ្ជីចំណាយ មានបង្ហាញនៅក្នុង *ឧបករណ៍ទី ១ : ថវិកាសហគ្រាសសម្រាប់អ្នកចិញ្ចឹមជ្រូក* នៅផ្នែកខាងចុងនៃសៀវភៅមគ្គុទ្ទេសក៏នេះ ។

**វដ្តផលិតកម្មជ្រូក និងតម្រូវការដើមទុន**

តម្រូវការដើមទុនប្រតិបត្តិការដ៏ចម្បងសម្រាប់អ្នកចិញ្ចឹមជ្រូក ទាក់ទងនឹងថ្លៃដែលត្រូវចាយវាយទៅលើការចិញ្ចឹម ជ្រូកក្នុងអំឡុងពេល ៤-៥ខែ ។

បច្ចុប្បន្ន ឥណទានភាគច្រើនបំផុតដែលផ្តល់ដល់ឧស្សាហកម្មចិញ្ចឹមជ្រូក គឺត្រូវបានផ្តល់តាមរយៈកម្ចីក្រៅផ្លូវការពីសំណាក់មិត្តភក្តិ និងគ្រួសារ (ឬពីអ្នករកស៊ីចងការប្រាក់ក្នុងមូលដ្ឋាន) ហើយឥណទានផ្គត់ផ្គង់ផ្នែកកសិកម្មរយៈពេលខ្លី ត្រូវបានផ្តល់ដោយអាជីវករចែកចាយចំណីសត្វក្នុងស្រុក ឬអាជីវករចែកចាយបន្ត ។ ឥណទានអ្នកផ្គត់ផ្គង់ អនុញ្ញាតអោយអ្នកចិញ្ចឹមជ្រូកសងថ្លៃចំណីសត្វ ក្នុងរយៈពេល ១០ ទៅ ១៤ថ្ងៃ នៅក្រោយពេលទិញ និងប្រគល់ ។ ជាធម្មតា ឥណទានរយៈពេលខ្លីទាំងនេះត្រូវសងនៅពេលប្រគល់ទំនិញលើកបន្ទាប់ ។ អ្នកចិញ្ចឹមជ្រូកចូលចិត្តបង់ជាសាច់ប្រាក់សុទ្ធសម្រាប់ការទិញកូនជ្រូក និងឱសថព្យាបាលជំងឺសត្វ ប៉ុន្តែអ្នកផ្គត់ផ្គង់ខ្លះលក់ឱសថ និងវ៉ាក់សាំង

ដោយអោយជំពាក់សិនជាមួយនឹងកិច្ចព្រមព្រៀងផ្តល់ឥណទានរយៈពេលខ្លី ដោយមានលក្ខខណ្ឌប្រហាក់ប្រហែលគ្នានឹងការលក់ចំណីសត្វដែរ ។

ការចិញ្ចឹមជ្រូកអាចត្រូវគេចាត់ទុកថាជាមុខរបរមួយដែលមានហានិភ័យខ្ពស់ ដោយសារតែវដ្តផលិតកម្ម រយៈពេល ៤-៥ខែសម្រាប់ការចិញ្ចឹមជ្រូកមួយក្បាល (ឬជ្រូកមួយហ្វូង) គឺវែងល្មមដែលតម្លៃអាចប្រែប្រួលខ្លាំងក្លា ជាពិសេសឆ្លើយតបទៅនឹងការប្រែប្រួលនៅក្នុងភាពបើកចំហនៃទីផ្សារកម្ពុជាចំពោះការនាំចូលពីប្រទេសជិតខាង ។ ការព្រួយបារម្ភក្នុងចំណោមអ្នកចិញ្ចឹមជ្រូកដែលថាតម្លៃនឹងប្រែប្រួលភ្លាមៗដែលជាហេតុនាំអោយគេខាតបង់ គឺជាឧបសគ្គរារាំងអ្នកចិញ្ចឹមជ្រូកភាគច្រើនមិនអោយខ្ចីប្រាក់ពីអ្នករកស៊ីអោយខ្ចីប្រាក់ជាផ្លូវការដូចជាធនាគារ និង ស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFI) ឡើយ ដោយសារពួកគេខ្លាចចំពោះការលោះយករបស់ដាក់បញ្ចាំមកវិញ (ដី និងផ្ទះ) ច្រើនជាងហានិភ័យផ្សេងទៀតទាំងអស់ ។

កម្មវិធីអោយខ្ចីប្រាក់សម្រាប់វិស័យកសិកម្មដែលបង្កើតឡើងនៅក្នុងឆ្នាំ២០០៧-២០០៨ ដោយធនាគារ និង MFI កម្ពុជាច្រើន ឆ្លើយតបទៅនឹងស្ថានការណ៍នេះដោយផ្តល់នូវលក្ខខណ្ឌសងប្រាក់ ដែលកំណត់ពេលវេលាស្របទៅនឹង វដ្តនៃផលិតកម្មកសិកម្ម ។ "កម្ចីសម្រាប់ផ្នែកកសិកម្ម" "កម្ចីដែលតម្រូវអោយបង់សងផ្តាច់ទាំងស្រុងតែមួយលើក" "កម្ចីដែលតម្រូវអោយសងរំលោះម្តងពាក់កណ្តាល" តម្រូវអោយបង់សងវិញនៅចុងបញ្ចប់នៃវដ្តផលិតកម្មតែមួយលើក ប៉ុន្តែកម្ចីជាច្រើនផ្តល់នូវលក្ខខណ្ឌសងវិញរយៈពេល១២ខែ ក្នុងករណីកើតមានការឡើងចុះតម្លៃ ដែលធ្វើអោយវដ្តផលិតមួយមិនអាចទទួលបានប្រាក់ចំណេញ ឬចំណេញតិចតួច ។ កម្ចីទាំងនេះគឺសមស្របបំផុតទៅនឹងតម្រូវការរបស់អាជីវកម្មផលិតជ្រូកកម្ពុជា ជាពិសេសប្រសិនបើប្រាក់ជំពាក់ដែលមិនទាន់សងនៅដំណាច់នៃរយៈពេល ១២ខែ អាចទទួលបានកម្ចីថ្មីទៀត ក្នុងករណីដែលលក្ខខណ្ឌទីផ្សារនៅតែមិនអំណោយផល ។ ចំណាត់ការបែបនេះ នឹងជាការចាំបាច់ ប្រសិនបើអ្នកផ្តល់ហិរញ្ញប្បទានកម្ពុជា ចង់ជួយទ្រទ្រង់កំណើនរបស់វិស័យផលិតកម្មជ្រូកអោយឈានដល់កម្រិតមួយដែលអាចប្រកួតប្រជែងជាមួយប្រទេសជិតខាងបាន ។

## *ការវាយតម្លៃផលិតករជ្រូកជាអ្នកខ្ចីប្រាក់*

ផលិតកម្មជ្រូកនៅទូទាំងពិភពលោក ត្រូវបានគ្រប់គ្រងដោយសមីការ "ធនធានដែលប្រើ-ទិន្នផល" តែមួយគត់ : តើបរិមាណសាច់ជ្រូកសុទ្ធ និងផលិតផលសាច់ជ្រូកផ្សេងទៀតប៉ុន្មានគីឡូក្រាម ដែលអាចផលិតបានក្នុងបរិមាណចំណីជាក់លាក់មួយ និងតើត្រូវចំណាយអ្វីខ្លះ ។ សូចនាករសំខាន់នៃប្រតិបត្តិការសម្រាប់អាជីវកម្មចិញ្ចឹមបំប៉នជ្រូកយកសាច់ ទាក់ទងនឹងល្បឿននិងប្រសិទ្ធភាពនៃការប្រែក្លាយពីចំណីទៅជាសាច់សត្វ ការរស់រាននៃសត្វជ្រូករហូតដល់ ពេលធំល្មមនឹងចាប់លក់ និងលទ្ធផលចុងក្រោយនៃផលិតផល - ជាកូនជ្រូកដែលល្មមសម្រាប់ការចិញ្ចឹមបំប៉ន ឬជាជ្រូកដែលមានទម្ងន់ប្រហែល ១០០គីឡូក្រាម ។

ហានិភ័យចំពោះឧស្សាហកម្មនេះ គឺភាគច្រើនកើតចេញពីជំងឺសត្វដែលធ្វើអោយជ្រូកងាប់នៅមុនពេលវាអាចត្រូវគេលក់ជាសាច់ ឬបន្ថយផលិតភាពនៃហ្វូងសត្វក្នុងការបង្កើតកូន និងក្នុងការផលិតសាច់សម្រាប់លក់ ។

ប្រតិបត្តិការផលិតជ្រូកដែលមានលក្ខណៈទំនើបបំផុតនៅលើពិភពលោក កត់ត្រា និងរក្សាទុកនូវបញ្ជីផលិតកម្ម និងបញ្ជីហិរញ្ញវត្ថុលំអិតបំផុតដើម្បីបង្ហាញអំពីលទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ពួកគេ ដោយប្រើប្រាស់ផលធៀបសាមញ្ញៗមួយចំនួនដែលពណ៌នាអំពីទិន្នផល និងប្រសិទ្ធភាពនៃការប្រែក្លាយពីចំណីសត្វទៅជាសាច់ជ្រូក សុខភាពនៃហ្វូងសត្វ និងល្បឿននៃការបន្តពូជ និងការឡើងទម្ងន់ ។

ផលិតករកម្ពុជាភាគច្រើនបំផុត មិនទាន់ឈានទៅដល់ភាពទំនើបផ្នែកគ្រប់គ្រងការងារកម្រិតបែបនេះនៅឡើយទេ ហើយមួយចំនួនតូចប៉ុណ្ណោះនៃពួកគេ ដែលធ្វើការកត់ត្រាបញ្ជីលំអិតគ្រប់គ្រាន់អំពីសកម្មភាពនិងការចំណាយរបស់ ពួកគេដើម្បីបង្ហាញអំពីលទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ខ្លួនអោយបានច្បាស់លាស់នោះ ។ ទោះបីជាយ៉ាងណាក៏ដោយ អាជីវករផលិតជ្រូកនៅកម្ពុជាជាច្រើនអាចរកស៊ីចំណេញទៅបាន ប្រសិនបើពួកគេទទួលបានជំនាញផ្នែកផលិតកម្ម ប្រតិបត្តិការកសិដ្ឋាន សុខភាពសត្វ ការគ្រប់គ្រងការចំណាយ និងការធ្វើម៉ាឃីតធីង ។

ដើម្បីធ្វើការវាយតម្លៃអាជីវករផលិតជ្រូកជាអ្នកខ្ចីប្រាក់ ស្ថាប័នមីក្រូហិរញ្ញវត្ថុនិងធនាគារកម្ពុជា អាចប្រើប្រាស់ការយល់ដឹងជាមូលដ្ឋានអំពីផលិតកម្ម ព្រមទាំងការអនុវត្តដែលទាក់ទងនឹងផលិតកម្មទាំងនេះ ដែលបង្កើនលទ្ធផលនៃប្រតិបត្តិការអាជីវកម្ម និងកាត់បន្ថយហានិភ័យនៃជំងឺសត្វ ។ *ឧបករណ៍ទី២ : បញ្ជីផ្ទៀងផ្ទាត់ការគ្រប់គ្រងហានិភ័យសម្រាប់ការវាយតម្លៃអាជីវករផលិតជ្រូក* គឺជាបញ្ជីផ្ទៀងផ្ទាត់អំពីចំណុចសំខាន់ៗសម្រាប់ការវាយតម្លៃអាជីវកម្មរបស់អ្នកចិញ្ចឹមជ្រូក ដោយផ្អែកលើការអនុវត្តតាមនូវវិធីគំរូ ដែលទាក់ទងនឹងកត្តានានាដែលទំនងជានឹងប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការអាជីវកម្មបំផុត ។

### លទ្ធផលនៃប្រតិបត្តិការចិញ្ចឹមជ្រូក

ការវាស់វែងលទ្ធផលនៃប្រតិបត្តិការចិញ្ចឹមជ្រូកជាមូលដ្ឋានសម្រាប់អ្នកទិញកូនជ្រូកយកទៅចិញ្ចឹមបំប៉នយកសាច់ គឺល្បឿនដែលជ្រូកឡើងទម្ងន់ ការចំណាយទៅលើការធ្វើអោយឡើងទម្ងន់នេះ និងទម្ងន់ចុងក្រោយនៅពេលដែលជ្រូកត្រូវបានចាប់លក់ (ពីព្រោះប្រការនេះ គឺជាកត្តាកំណត់តម្លៃលក់) ។ អ្នកចិញ្ចឹមជ្រូកដែលប្រើប្រាស់ពូជជ្រូកល្អ និងចំណីគ្រប់គ្រាន់ គួរតែអាចចិញ្ចឹមជ្រូកអោយធំធាត់ និងលក់នៅពេលវាឡើងដល់ "ទម្ងន់ដែលទីផ្សារត្រូវការ" គឺ ប្រហែលជា ១០០គីឡូក្រាម នៅក្នុងរយៈពេលប្រហែល ៤ខែកន្លះ ។ ជ្រូកធំធាត់យឺតនៅក្រោយរយៈពេល ៤ខែ ហើយថ្លៃចំណាយទៅលើការចិញ្ចឹមវា នឹងលើសទម្ងន់ដែលទទួលបានបន្ថែមនៅក្រោយពេលនោះ ដែលធ្វើអោយផលិតកម្មមិនសូវទទួលបានផលចំណេញឡើយ ។

ចំពោះអ្នកផលិតកូនជ្រូក ការគ្រប់គ្រងអោយបានច្បាស់លាស់នូវភាពអំណោយផលនៃសត្វបង្កាត់ពូជ - ជាពិសេស គឺជ្រូកមេ - គឺជាប្រការដែលរឹតតែសំខាន់ថែមទៀត ។ ហេតុដូច្នេះហើយ ផលិតកម្មកូនជ្រូកមានសូចនាករវាស់វែងលទ្ធផលនៃប្រតិបត្តិការដែលពាក់ព័ន្ធច្រើនជាង ។ វាពិបាកនឹងរកបានប្រាក់ចំណេញក្នុងរយៈពេលវែង ប្រសិនបើអ្នកផលិតមិនមានការអនុវត្តបានល្អត្រឹមត្រូវ មិនគ្រប់គ្រងពេលវេលារវាងពីការបង្កាត់ពូជមួយលើកទៅការបង្កាត់ពូជមួយលើកទៀត និងមិនធានានូវការរស់រាននៃកូនជ្រូកដែលទើបនឹងកើតទេនោះ ។

## ការរៀបចំ និងការគ្រប់គ្រងកសិដ្ឋាន

**ដង់ស៊ីតេជ្រូកក្នុងទ្រុង**

ជ្រូកត្រូវការកន្លែងសមស្របដែលរៀបចំបានល្អដើម្បីអោយវាមានសុខភាពល្អ និងធំធាត់ក្នុងអត្រាសមស្រប ។ មន្ត្រីផ្នែកកម្ចីអាចពិនិត្យមើលដឹងភ្លាមៗ ថាតើអ្នកផលិតជ្រូករៀបចំទ្រុងសម្រាប់ជ្រូកបានសមស្របដោយមានទំហំធំល្មមឬក៏អត់ ហើយប្រការនេះក៏ជាការបង្ហាញអោយឃើញថាតើអ្នកផលិតជ្រូកហ្នឹងគ្រប់គ្រងប្រតិបត្តិការរបស់ខ្លួន ដោយហ្មត់ចត់ ឬអត់ ផងដែរ ។

**ការផ្តល់ទឹក**

ទឹកគឺជាធនធានដ៏ចាំបាច់សម្រាប់ផលិតកម្មជ្រូក ហើយក៏ជាកត្តាដ៏សំខាន់សម្រាប់ការវាយតម្លៃសុខភាពសត្វ និងការគ្រប់គ្រង ។ ទឹកអណ្តូងគឺជាប្រភពដែលល្អប្រសើរ ប៉ុន្តែគេត្រូវមានការប្រុងប្រយ័ត្ននៅពេលប្រើប្រាស់ទឹកពីក្រោមដីនេះ ដោយសារតែភាពកខ្វក់នៅក្នុងទឹកដែលអាចបណ្តាលទៅជាបញ្ហាសុខភាព ។ គួរជៀសវាងការប្រើទឹកស្រះ ឬត្រពាំង ។

ជាទូទៅ ការផ្តល់ទឹកដល់សត្វជ្រូកគឺមានលក្ខណៈសាមញ្ញបំផុត ។ ទុយោទឹកដែលតភ្ជាប់ទៅរោងចិញ្ចឹមជ្រូក គួរតែការពារអោយបានត្រឹមត្រូវដើម្បីជៀសវាងការខូចខាត ។ "ឧបករណ៍បន្សាចទឹកដោយស្វ័យប្រវត្តិ" គឺជាជម្រើសជាទូទៅរបស់អ្នកចិញ្ចឹមជ្រូកដែលមានបទពិសោធន៍ ។ ទីតាំងនៃឧបករណ៍នេះ និងចំនួនជ្រូកដែលប្រើឧបករណ៍នីមួយៗ គឺជាសូចនាករដែលអាចបង្ហាញថា អ្នកចិញ្ចឹមជ្រូកយល់ដឹងអំពីវិធីធានាសុខភាព និងការធំធាត់នៃសត្វចិញ្ចឹមរបស់ខ្លួន ។

**ការចាត់ចែងលាមកសត្វ**

ការគ្រប់គ្រងកាកសំណល់សម្រាប់ប្រតិបត្តិការដែលមានទ្រង់ទ្រាយធំ ជារឿយៗត្រូវការកម្លាំងពលកម្មច្រើន ។ ការប្រមូលលាមកជ្រូកចេញពីទ្រុង ចេញពីអគារ និងយកទៅទុកនៅទីវាល ត្រូវតែធ្វើផែនការអោយបានហ្មត់ចត់ នៅមុនពេលដែលប្រតិបត្តិការចិញ្ចឹមជ្រូករីកកាន់តែធំ ។ នៅពេលចាត់ចែងលាមកសត្វ អ្នកផលិតគួរតែដឹងអំពីកត្តា ដែលអាចបង្កគ្រោះថ្នាក់ដល់សុខភាព និងគួរចេះគិតគូរចំពោះអ្នកជិតខាង ។

អ្នកផលិតជ្រូកនៅកម្ពុជាជាច្រើនដំឡើងឧបករណ៍បំប្លែងលាមកសត្វ ដែលត្រូវបានស្ថាបនានៅក្នុងខេត្តចំនួន ៧ តាមរយៈកម្មវិធីមួយឈ្មោះថា National Biodigester Program ។ ការដំឡើងឧបករណ៍បំប្លែងលាមកសត្វមួយ ត្រូវចំណាយប្រាក់យ៉ាងតិចបំផុត ៤០០ ដុល្លារ ។ ឧបករណ៍នេះអាចបំប្លែងលាមកជ្រូក និងគោទៅជាល្បាយជីដែលមានគុណភាពខ្ពស់ និងផលិតឧស្ម័នមេតានសម្រាប់បម្រើសេចក្តីត្រូវការផ្នែកចម្អិន និងភ្លើងបំភ្លឺ ។ នេះគឺជាប្រព័ន្ធគ្រប់គ្រងលាមកសត្វដ៏សំខាន់មួយសម្រាប់អ្នកផលិតជ្រូកដែលមានចំនួនកើនឡើងកាន់តែច្រើន និងជាការវិនិយោគទុនដ៏សំខាន់នៅក្នុងប្រតិបត្តិការផលិតជ្រូក ។

## សុខភាពសត្វ

នៅក្នុងប្រទេសកម្ពុជា ជំងឺសត្វដ៏មានគ្រោះថ្នាក់កើតមានគ្រប់ទិសទី ។ អ្នកផលិតជ្រូកដែលពូកែចាត់វិធានការដើម្បីការពារប្រតិបត្តិការកសិដ្ឋានចិញ្ចឹមជ្រូករបស់ពួកគេ ។ ទិដ្ឋភាពសំខាន់ៗមួយចំនួននៃការថែទាំសុខភាពសត្វ និងការបង្ការជំងឺ រួមមាន : (១) ការទិញជ្រូកសម្រាប់បង្កាត់ពូជ ឬកូនជ្រូកសម្រាប់ចិញ្ចឹមបំប៉នយកសាច់ពីប្រភពដែលស្គាល់ច្បាស់ (២) ថែទាំកន្លែងចិញ្ចឹមអោយស្អាត និងមានអនាម័យ និងរក្សាអោយមានខ្យល់ចេញចូលគ្រប់គ្រាន់ (៣) ការធ្វើផែនការសម្រាប់សុខភាពសត្វ ។

ជាធម្មតា ការធ្វើផែនការសុខភាពសត្វ រួមមានវិធានការសម្រាប់ (១) ការកាត់បន្ថយហានិភ័យនៃជំងឺថ្មី ដែលឆ្លងតាមរយៈការបន្ថែមសត្វ ឬភ្ញៀវ (ដូចជា អ្នកទិញ) (២) ការរក្សាអនាម័យ (៣) ការព្យាបាល ឬទម្លាក់ សត្វល្អិតប្រភេទបារ៉ាសិត (៤) ការបង្ការ និងគ្រប់គ្រងជំងឺផ្នែកផ្លូវដង្ហើម ជំងឺផ្នែកប្រព័ន្ធបន្តពូជ និងជំងឺរាក ។

អ្នកផលិតជ្រូកនៅកម្ពុជាដែលមានបទពិសោធន៍ ផ្តល់វ៉ាក់សាំង និងការព្យាបាលសម្លាប់បារ៉ាសិតជាទៀងទាត់ដល់ជ្រូករបស់ពួកគេ និងព្យាបាលជំងឺផ្សេងៗទៀតភ្លាមៗ ។ ការអនុវត្តវិធានគ្រប់គ្រងកសិដ្ឋានបានល្អ ក៏ចូលរួមចំណែកដល់ការកាត់បន្ថយហានិភ័យនៃការឆ្លងជំងឺ និងលើកកម្ពស់សុខភាពសត្វ ។

## ការគ្រប់គ្រង និងចាត់ចែងការចំណាយ

### ចំណីសត្វ

ចំណីសត្វ គឺជាការចំណាយដ៏ចម្បងនៃគ្រប់ប្រព័ន្ធផលិតកម្មជ្រូក ។ ជាទូទៅ ប្រតិបត្តិការបង្កើតកូនជ្រូកនិងចិញ្ចឹម បំប៉នលក់ជាជ្រូកសាច់ នឹងចំណាយ ៧៥%នៃការចំណាយសរុបទៅលើចំណីសត្វ បើប្រៀបធៀបទៅនឹងប្រតិបត្តិការ បង្កើតនិងលក់កូនជ្រូកដែលមាន ៥០% និងប្រតិបត្តិការទិញកូនជ្រូកយកទៅចិញ្ចឹមបំប៉នលក់ជាជ្រូកសាច់ ដែលមាន ៦៥% ។

អ្នកចិញ្ចឹមជ្រូកខ្នាតតូចបំផុតនៅកម្ពុជា តាមទំនៀមទម្លាប់ គឺពឹងផ្អែកទៅលើកាកសំណល់ម្ហូបអាហារនៅផ្ទះបាយ និងកន្ទក់សម្រាប់ជាចំណីសត្វដែលធ្វើអោយលទ្ធផលនៃការចិញ្ចឹមមានភាពមិនសមស្រប ។ អ្នកចិញ្ចឹមដែលមាន ទ្រង់ទ្រាយធំជាងនេះ (SME) ជាធម្មតាប្រើប្រាស់ចំណីសត្វ (លាយ) ដែលផលិតដោយរោងចក្រពីក្រុមហ៊ុន CP Group, Medivet និង Worldvet និង Thom Thom ។ ពួកគេធ្វើដូច្នេះដើម្បីផ្តល់ចំណីដែលមានគុណភាព អាចទស្សន៍ទាយបានដល់ជ្រូក ដែលនាំអោយអត្រានៃការចំលូតលាស់ និងទិន្នផលសាច់មានភាពប្រសើរជាង ។

ប៉ុន្តែទោះជាយ៉ាងណា ការពឹងផ្អែកលើចំណីសត្វលាយដែលផលិតដោយរោងចក្រអាចចំណាយអស់ប្រាក់ច្រើន ។ អ្នកផលិតជ្រូកដែលមានបទពិសោធន៍ ជារឿយៗ ដាក់លាយចំណីសត្វទិញពីរោងចក្រជាមួយនឹងគ្រឿងផ្សំផ្សេងៗ ទៀត ដូចជា កន្ទក់ ពោត សាច់ត្រី និងបាយស្រា ។ ការលាយចំណីសត្វច្រើនមុខអាចទទួលយកបាន ប្រសិនបើអ្នកផលិតទទួលបានអត្រាធំធាត់នៃជ្រូកល្អប្រសើរ ខណៈដែលការគ្រប់គ្រងថ្លៃចំណាយផលិតកម្មបានល្អដែរនោះ ។ កត្តាដែលសំខាន់បំផុត គឺវាយតម្លៃមើលថាតើអ្នកផលិតដឹងអំពីលទ្ធភាពរបស់ពួកគេក្នុងការគ្រប់គ្រងថ្លៃចំណាយ តាមរយៈប្រព័ន្ធផ្តល់ចំណីលាយចម្រុះ ឬអត់ ។

អ្នកផលិតដែលមានបច្ចេកទេសទំនើបខ្លាំង អាចដាំដុះធញ្ញជាតិដោយខ្លួនឯង ទិញគ្រឿងផ្សំម្តងច្រើនៗ និងប្រើប្រាស់ឧបករណ៍កិន និងលាយផ្ទាល់ខ្លួនដើម្បីកាត់បន្ថយថ្លៃចំណាយទៅលើចំណី ។ ប៉ុន្តែការទុកដាក់អោយបានសមស្របនូវគ្រឿងផ្សំចំណីសត្វដែលមានបរិមាណច្រើន គឺជាការចាំបាច់ ។ សមាគមចិញ្ចឹមជ្រូកនៅកម្ពុជាមួយចំនួន កំពុងខិតខំធ្វើការឆ្ពោះទៅរកការផលិត ឬលាយចំណីសត្វជាលក្ខណៈក្នុងស្រុកដើម្បីជួយដល់អ្នកផលិតជ្រូកនៅក្នុងកិច្ចប្រឹងប្រែងកាត់បន្ថយថ្លៃចំណាយ ។

## ការកត់ត្រាបញ្ជី

ការកត់ត្រាបញ្ជីបានល្អត្រឹមត្រូវ គឺជាគន្លឹះសម្រាប់ការចាត់ចែងការងារ ការគ្រប់គ្រងថ្លៃចំណាយបានល្អប្រសើរ និងភាពអាចរកបានប្រាក់ចំណេញក្នុងរយៈពេលវែងនៅក្នុងអាជីវកម្មចិញ្ចឹមជ្រូក ។

បញ្ជីដែលអ្នកផលិតជ្រូកត្រូវរក្សាទុកនោះ មាន ៣ប្រភេទ : បញ្ជីហិរញ្ញវត្ថុ បញ្ជីផលិតកម្ម និងបញ្ជីព័ត៌មាន ។ ការដឹងអំពីបញ្ជីអ្វីខ្លះដែលអ្នកផលិតជ្រូករក្សាទុក អាចជួយអ្នកផ្តល់ប្រាក់កម្ចីអោយបានយល់អំពីថាតើពួកគេមានភាពម៉ឺងម៉ាត់ជាមួយនឹងអាជីវកម្មរបស់ពួកគេយ៉ាងណា និងអំពីថាតើពួកគេកំពុងសកម្មក្នុងការស្វែងរកឱកាសដើម្បីគ្រប់គ្រងថ្លៃចំណាយ និងលើកកម្ពស់លទ្ធភាពរកប្រាក់ចំណេញដែរឬយ៉ាងណា ។

បញ្ជីផលិតកម្មសម្រាប់អ្នកទិញកូនជ្រូកមកចិញ្ចឹមបំប៉នដើម្បីលក់ជាជ្រូកសាច់ យ៉ាងហោចណាស់ គួររួមបញ្ចូលនូវព័ត៌មានដូចជាប្រភពដើមនៃកូនជ្រូក កាលបរិច្ឆេទនៃការទិញកូនជ្រូក ទម្ងន់ជ្រូកនៅពេលទិញ កាលបរិច្ឆេទនៃការលក់ ទម្ងន់ជ្រូកនៅពេលលក់ និងកាលបរិច្ឆេទនៃការផ្តល់វ៉ាក់សាំងនិងការព្យាបាលសម្លាប់ប៉ារ៉ាសិត ។

លក្ខខណ្ឌតម្រូវនៃការកត់ត្រាបញ្ជីផលិតកម្មសម្រាប់ប្រតិបត្តិការបង្កើតកូនជ្រូក (អ្នកបង្កាត់ពូជនិងលក់កូនជ្រូក) គឺ មានភាពស្មុគស្មាញជាងបញ្ជីផលិតកម្មសម្រាប់ប្រតិបត្តិការទិញកូនជ្រូកចិញ្ចឹមបំប៉នដើម្បីលក់ជាជ្រូកសាច់ ។ ពេលវេលានៃការបង្កាត់ពូជជ្រូក គួរត្រូវបានគ្រប់គ្រងច្បាស់លាស់ ដើម្បីធានានូវលទ្ធភាពរកបានប្រាក់ចំណេញខ្ពស់បំផុត ហើយបញ្ជីនេះគឺជាការចាំបាច់សម្រាប់ការរកអោយឃើញនិងកែតម្រូវបញ្ហា នៅពេលដែលវាកើតមានឡើង ។ បញ្ជីផលិតកម្មដែលសំខាន់សម្រាប់អាជីវកម្មបង្កើតកូនជ្រូក រួមមានកាលបរិច្ឆេទនៃការផ្តាច់ដោះ កាលបរិច្ឆេទនៃការបង្កាត់ពូជ ទំហំកូនជ្រូក និងការរស់រាន ព្រមទាំងកាលបរិច្ឆេទនៃការចាក់វ៉ាក់សាំង និងការព្យាបាលសម្លាប់ប៉ារ៉ាសិតដល់មេជ្រូក និងកូនជ្រូក ។

ដោយសារតែអាជីវកម្មផលិតជ្រូកនៅកម្ពុជាភាគច្រើនបំផុតផ្អែកលើសាច់ប្រាក់សុទ្ធ បញ្ជីនៃការទិញនិងការចំណាយ គឺជាសញ្ញាមួយបង្ហាញអំពីភាពហ្មត់ចត់នៅក្នុងការគ្រប់គ្រងអាជីវកម្ម ។ ទម្រង់គំរូនៃបញ្ជីចំណូលនិងចំណាយប្រចាំ ខែ ដែលអាចថតចម្លងនិងចែកចាយដោយសេរីដល់អ្នកចិញ្ចឹមជ្រូក គឺមានភ្ជាប់ជាមួយនៅក្នុង *ឧបករណ៍ទី ៣ : បញ្ជីអាជីវកម្ម ចិញ្ចឹមជ្រូក* នៅផ្នែកខាងចុងនៃសៀវភៅនេះ ។ គម្រោង MSME លើកទឹកចិត្តអោយអ្នកធ្វើការចែកចាយ ទម្រង់បញ្ជីនេះដល់អតិថិជនរបស់អ្នកដែលមកពីវិស័យឧស្សាហកម្មជ្រូក និងផ្តល់នូវព័ត៌មានជាមូលដ្ឋានស្តីពីរបៀបបំពេញទម្រង់បញ្ជីនេះ ។

**ម៉ាឃីតធីង (ការរកទីផ្សារលក់)**

បញ្ហាម៉ាឃីតធីង គឺសំខាន់ខ្លាំងណាស់ចំពោះអ្នកចិញ្ចឹមជ្រូកនៅកម្ពុជា ។ ទីផ្សារជ្រូកនៅកម្ពុជា បានត្រូវទទួលរងនូវការប្រកួតប្រជែងជាច្រើនពីជ្រូកនាំចូលពីប្រទេសថៃនិងប្រទេសវៀតណាម ហេតុដូច្នេះហើយ វាមានលក្ខណៈផ្សារភ្ជាប់ជាមួយនឹងវដ្តផលិតកម្មយ៉ាងខ្លាំង ។

អ្នកចិញ្ចឹមជ្រូកនៅកម្ពុជា ពុំទាន់បានបង្កើតនូវយុទ្ធសាស្ត្រដែលមានប្រសិទ្ធភាពដើម្បីដោះស្រាយបញ្ហានៃការឡើងចុះតម្លៃ និងហានិភ័យនៅលើទីផ្សារដែលបណ្តាលមកពីការឡើងចុះនេះនៅឡើយទេ ប៉ុន្តែទោះជាយ៉ាងនេះក្តី កិច្ចប្រឹងប្រែងជាច្រើនក្នុងការកសាងឃីហោជ្រូកនៅតាមខេត្ត ការចងក្រងជាសមាគម និងការបង្កើតទំនាក់ទំនងល្អ ប្រសើរជាមួយអ្នកទិញ កំពុងត្រូវបានអនុវត្ត ។ ទោះជាយ៉ាងណាសូម្បីតែអ្នកចិញ្ចឹមជ្រូកប្រកបដោយលក្ខណៈអាជីពត្រឹមត្រូវ ជារឿយៗ ក៏ផ្អាកអាជីវកម្មបណ្តោះអាសន្នផងដែរនៅក្នុងអំឡុងពេលដែលមានការនាំចូលច្រើន និងចាប់ផ្តើមប្រតិបត្តិការឡើងវិញនៅពេលដែលលក្ខខណ្ឌទីផ្សារមានភាពអនុគ្រោះជាងមុន ។

**<u>ការជ្រើសរើសពូជ</u> :**

អ្វីដែលទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងបញ្ហាម៉ាឃីតធីង គឺការជ្រើសរើសពូជជ្រូករបស់អ្នកចិញ្ចឹម ។ មានជម្រើសពូជជ្រូកជាច្រើនដែលអាចទទួលយកបាន ប៉ុន្តែប្រភេទពូជជ្រូកនីមួយៗសុទ្ធតែមានទាំងហានិភ័យ និងមានទាំង ផលប្រយោជន៍ ។ ការកែលម្អពូជជ្រូក គឺជាប្រការមួយក្នុងចំណោមប្រការជាច្រើន ដែលអ្នកចិញ្ចឹមជ្រូកនៅកម្ពុជា ត្រូវធ្វើមុនដំបូងគេ នៅពេលពួកគេប្រែក្លាយពីការចិញ្ចឹមបន្តិចបន្តួច នៅក្រោយផ្ទះទៅជាប្រតិបត្តិការអាជីវកម្មខ្នាតតូចនោះ ។

ពូជជ្រូកកូនកាត់ (ពូជល្អ ឬពូជដែលមានហ្សេនទិចខ្ពស់) គឺពូជជ្រូកដែលកើតចេញពីពូជដែលមានដើមកំណើតពីក្រៅស្រុកដែលមានលក្ខណៈល្អ បង្កាត់ជាមួយពូជជ្រូកខ្មែរដែលតែងចិញ្ចឹមជាប្រពៃណី ។ ពូជជ្រូកកូនកាត់ នៃប្រភេទទាំងនេះ ច្រើនតែមានរួមបញ្ចូលគ្នានូវលក្ខណៈល្អៗច្រើន - ជាពិសេស ទិន្នផលសាច់មិនសូវមានខ្លាញ់ - និងមានប្រព័ន្ធទប់ទល់នឹងជំងឺខ្លាំងក្លា និងសម្របខ្លួនបានល្អជាមួយនឹងលក្ខខណ្ឌអាកាសធាតុត្រូពិក ។

ជាទូទៅ ទីផ្សារនៅក្នុងក្រុងភ្នំពេញនិងខេត្តសៀមរាប ត្រូវការខ្លាំងនូវសាច់ជ្រូកមិនសូវមានខ្លាញ់ដែលផ្តល់ដោយពូជជ្រូកកូនកាត់ ដូចជាពូជជ្រូកដែលផ្តល់ដោយក្រុមហ៊ុន CP និងអាជីវកម្មផលិតកូនជ្រូកដោយខ្លួនឯងធំៗ ។

ពូជជ្រូក"ធម្មតា" - ពូជជ្រូកនៅកម្ពុជា - ច្រើនតែមានសារធាតុខ្លាញ់ខ្ពស់ និងសាច់សុទ្ធតិច ។ ពូជជ្រូកទាំងនេះ អាចនឹងជាតម្រូវការរបស់ទីផ្សារក្នុងភូមិ ប៉ុន្តែមិនសូវមានលក្ខណៈទាក់ទាញចំពោះទីផ្សារនៅទីក្រុងឡើយ ។ ការសិក្សាស្រាវជ្រាវរបស់គម្រោង MSME បង្ហាញថា កសិករទទួលបានផលចំណូលពីពូជជ្រូកធម្មតា (ពូជក្នុងស្រុក) ចន្លោះពី ២០% ទៅ ៣០% តិចជាងផលចំណូលដែលគេទទួលបានពីពូជជ្រូកកែលម្អ (ពូជជ្រូកកូនកាត់ ឬពូជជ្រូកដែលមានហ្សេនទិចខ្ពស់) ។ ពូជជ្រូកកូនកាត់ទាំងនេះ ហាក់ដូចជាផ្សាំខ្លួនបានយ៉ាងល្អប្រសើរជាមួយនឹងលក្ខខណ្ឌនៅក្នុងប្រទេសកម្ពុជា ហើយអាចទប់ទល់នឹងជំងឺបានខ្លាំងជាង ។

ការចិញ្ចឹមពូជជ្រូកកូនកាត់អោយបានជោគជ័យ គឺត្រូវការនូវចំណីសត្វ ឱសថ/វ៉ាក់សាំងថ្លៃ និងដើមទុន ព្រមទាំងជំនាញបច្ចេកទេសច្រើនជាងការចិញ្ចឹមជ្រូកពូជក្នុងស្រុក ។

កត្តាដែលសំខាន់បំផុតនៅក្នុងការវាយតម្លៃភាពស័ក្តិសមនឹងទទួលបានឥណទានរបស់អ្នកចិញ្ចឹមជ្រូក គឺ*របៀបដែលអ្នកចិញ្ចឹមជ្រូកផ្សារភ្ជាប់ជម្រើសពូជជ្រូករបស់ខ្លួនជាមួយនឹងទីផ្សារដែលខ្លួនចង់បម្រើ* ។ អ្នកចិញ្ចឹមជ្រូកដែលមិន ដឹងអំពីសេចក្តីត្រូវការនៃទីផ្សារដែល

ពួកគេបម្រើ គឺច្រើនតែទទួលបានតម្លៃទាបសម្រាប់ផលិតផលរបស់ពួកគេ និងអាចធ្លាក់ក្នុងស្ថានភាពរកទីផ្សារសម្រាប់លក់ជ្រូករបស់ខ្លួនមិនបាននៅក្នុងអំឡុងពេលដែលការនាំចូលកើនខ្ពស់ ។

**ទំនាក់ទំនងជាមួយអ្នកទិញ :**

អ្នកចិញ្ចឹមជ្រូកទ្រង់ទ្រាយតូចនិងមធ្យម ជាធម្មតាតែងលក់ជ្រូកទៅអោយឈ្មួញប្រមូលទិញក្នុងស្រុក ទៅអោយអាជីវករទិញ-លក់ក្នុងទ្រង់ទ្រាយធំ ឬលក់ផ្ទាល់ទៅអោយកន្លែងកាប់ (ទីសត្តឃាត) ។ ទាំងចំនួននិងទាំងគុណភាព នៃទំនាក់ទំនងជាមួយអ្នកទិញ គឺជាកត្តាកំណត់ដ៏សំខាន់អំពីជោគជ័យរបស់អ្នកចិញ្ចឹមជ្រូកទ្រង់ទ្រាយតូច ។

អ្នកចិញ្ចឹមជ្រូកដែលមានលក្ខណៈអាជីពខ្ពស់ (អ្នកចិញ្ចឹមបំប៉នដើម្បីលក់ជាជ្រូកសាច់) យល់អំពីតម្រូវការគុណភាពរបស់ទីផ្សារធំៗ ទីផ្សារអ្នកមាននៅក្នុងប្រទេសកម្ពុជា (សាច់ជ្រូកដែលមានខ្លាញ់តិច ។ល។) និងមាន (១) ទំនាក់ទំនងរឹងមាំជាមួយអ្នកទិញច្រើននាក់ ឬក្នុងករណីមិនសូវញឹកញាប់ (២) កិច្ចព្រមព្រៀងរយៈពេលវែងជាមួយអ្នក ទិញតែម្នាក់ ដែលជួនកាលជាសមាជិកគ្រួសារ ។ ប្រការនេះផ្តល់នូវកម្រិតស្ថិរភាពខ្ពស់សម្រាប់ការលក់ជ្រូក ។

ទីផ្សាររបស់អ្នកផលិតកូនជ្រូក (អ្នកបង្កាត់ពូជនិងបង្កើតកូនជ្រូក) មានភាពពឹងផ្អែកខ្លាំងទៅលើសកម្មភាពរបស់អ្នកចិញ្ចឹមជ្រូកក្នុងស្រុក ដែលកើតចេញពីតម្រូវការទីផ្សារចុងក្រោយបំផុត ។ កូនជ្រូកពិបាកនឹងលក់ចេញ នៅពេលដែលអ្នកចិញ្ចឹមជ្រូកបំប៉នដើម្បីលក់ជាជ្រូកសាច់ គ្មានភាពជឿជាក់ទៅលើលទ្ធភាពរបស់ពួកគេដើម្បីលក់ជ្រូកដែលចិញ្ចឹមធំ ។ តម្លៃកូនជ្រូកឡើងខ្ពស់ខ្លាំង នៅក្នុងអំឡុងពេលនៃរដូវដែលមានតម្រូវការខ្ពស់ ។ ដោយសារតែប្រតិបត្តិការរួមបញ្ចូលគ្នា (បង្កាត់ពូជ និងបង្កើតកូនជ្រូក) ស្រូបយកនូវហានិភ័យផ្អែកទីផ្សារទាំង២ប្រភេទនេះ ប្រតិបត្តិការនេះអាចរកបានប្រាក់ចំណេញច្រើននៅពេលដែលមានតម្រូវការខ្ពស់ ប៉ុន្តែត្រូវការនូវការចំណាយច្រើនដើម្បីចិញ្ចឹមថែរក្សាសត្វដែលត្រូវបង្កាត់ពូជអោយនៅមានជីវិត និងមានផលិតភាពនៅក្នុងអំឡុងពេលដែលតម្រូវការធ្លាក់ចុះ ដែលមានប្រាក់ចំណូលទាប ។

**កេរ្តិ៍ឈ្មោះ :**

កេរ្តិ៍ឈ្មោះ គឺជាកត្តាសំខាន់ជាពិសេសសម្រាប់អ្នកបង្កាត់ពូជនិងបង្កើតកូនជ្រូក ។ កេរ្តិ៍ឈ្មោះសម្រាប់ការផ្គត់ផ្គង់ នូវកូនជ្រូកដែលមានសុខភាពល្អ និងមានផលិតភាពខ្ពស់ ដែលអាចធំធាត់ទៅជាជ្រូកដែលងាយលក់ចេញទៅអោយទីផ្សារ បង្ហាញថា អ្នកផលិតកូនជ្រូកនោះ គឺជាអ្នកដែលមានជំនាញខ្ពស់ជាមួយនឹងមូលដ្ឋានអតិថិជនគ្រប់គ្រាន់ ។

## ឧបករណ៍ទី ១ : ថវិការបស់សហគ្រាសសម្រាប់ការចិញ្ចឹមជ្រូក

ថវិកាប្រតិបត្តិការដែលមាននៅក្នុងផ្នែកនេះ បង្ហាញអំពីរបៀបគណនាថាតើប្រតិបត្តិការចិញ្ចឹមជ្រូកអាចរកប្រាក់ចំណេញបានដែរឬទេ ផ្អែកលើព័ត៌មានអំពីតម្លៃលក់ដែលរំពឹងទុក និងថ្លៃចំណាយក្នុងការចិញ្ចឹមជ្រូក ។

ថវិកាទាំងនេះក៏អាចពន្យល់ហេតុផលអំពីការខាតបង់ ដោយសារជ្រូក ឬមេជ្រូកងាប់ ដូច្នេះការប្រមូលព័ត៌មានពីអ្នកផលិតអំពីការខាតបង់ជាធម្មតាទៅលើហ្វូងជ្រូករបស់ពួកគេ នឹងធ្វើអោយថវិកាកាន់តែមានភាពត្រឹមត្រូវ ។

អ្នកអាចទទួលបានថវិកាទាំងនេះ នៅក្នុងទម្រង់អេឡិចត្រូនិក ដោយទាក់ទងគម្រោង Cambodia MSME ដោយផ្ទាល់ និងស្នើអោយពួកគេនិយាយទៅកាន់ក្រុមផលិតកម្មជ្រូក ។

## ថវិកាគំរូ : ចំណាយមិនឆ្លុះបញ្ចាំងពីស្ថានភាពបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាឡើយ ៕

### ថវិកាគំរូសម្រាប់ចិញ្ចឹមជ្រូក ~ មួយក្បាល

| ចំណូល | ថ្លៃ | ឯកតា | | បរិមាណ | ឯកតា | | សរុប |
|---|---|---|---|---|---|---|---|
| ជ្រូកទីផ្សារ | $2.00 | ក្នុង១គក្រ | x | 100 | គក្រ | = | $200.00 |
| **ចំណាយប្រែប្រួល** | **ថ្លៃ** | **ឯកតា** | | **បរិមាណ** | **ឯកតា** | | |
| ជ្រូកពូជ (កូនជ្រូក) | $50.00 | ក្បាល | x | 1 | ក្បាល | = | $50.00 |
| ការប្រាក់ចំពោះប្រាក់ខ្ចីសម្រាប់កូនជ្រូក | 24% | | x | 0 | ខែ | = | $0.00 |
| **ចំណាយលើចំណី** | | | | | | | |
| ចំណីផ្សំ | $0.50 | ក្នុង១គក្រ | x | 200.0 | គក្រ | = | $100.00 |
| កន្ទក់ | $0.17 | ក្នុង១គក្រ | x | 82 | គក្រ | = | 13.94 |
| ពោត | $0.06 | ក្នុង១គក្រ | x | 32 | គក្រ | = | 1.92 |
| គ្រឿងផ្សំដទៃទៀត ១ | $0.30 | ក្នុង១គក្រ | x | 5.0 | គក្រ | = | 1.50 |
| គ្រឿងផ្សំដទៃទៀត ២ | $10.00 | ក្នុង១គក្រ | x | 0.3 | គក្រ | = | 3.00 |
| សារធាតុបន្ថែមលើចំណី | | | | | | | 3.00 |
| ផ្សេងៗ (ឧ. ប្រដាប់ដាក់ទឹកផឹក) | | | | | | | 0.15 |
| **ចំណាយលើចំណីសរុប** | | | | | | | $123.51 |
| ការព្យាបាល និងថ្នាំ | | | | | | | $4.00 |
| ប្រេង ជួសជុល សេវាសាធារណៈ | | | | | | | 3.50 |
| ទីផ្សារ និងចំណាយបន្ទាប់បន្សំ | | | | | | | 4.00 |
| ផ្សេងៗ | | | | | | | 0.00 |
| ចំណាយលើជីលាមកសត្វ | $0.01 | ក្នុង១សំបុក | | 190 | សំបុក | = | 1.90 |
| ការប្រាក់លើចំណាយប្រែប្រួល | 24% | ក្នុង១ឆ្នាំ | | 0 | ខែ | = | 0.00 |
| ខាតបង់ដោយសារជ្រូកងាប់ | 0.05 | hd | | | | = | 2.50 |
| កម្លាំងពលកម្ម | $0.25 | ក្នុង១ម៉ោង | | 0.2 | ម៉ោង | = | 0.05 |
| **ចំណាយប្រែប្រួលសរុប** | | | | | | | $189.46 |
| **ចំណូល (ប្រាក់ចំណេញ) លើចំណាយប្រែប្រួល** | | | | | | | $10.54 |
| **ចំណាយថេរ** | | | | | | | |

| | | |
|---|---|---|
| គ្រឿងចក្រ បរិក្ខារ | | $2.50 |
| **សរុបចំណាយទាំងអស់** | | $191.96 |
| **ចំណូល (ប្រាក់ចំណេញ) លើចំណាយសរុប** | **ចំណូលដក (-) ចំណាយទាំងអស់** | **$8.04** |
| ថ្លៃលក់ស្មើដើមសម្រាប់ចំណាយប្រែប្រួល | **ចំណាយប្រែប្រួលសរុបចែក (÷) ចំណូល** | $1.89 |
| ថ្លៃលក់ស្មើដើមសម្រាប់ចំណាយទាំងអស់ | **សរុបចំណាយទាំងអស់ចែក (÷) ចំណូល** | $1.92 |

## ថវិកាគំរូ : ចំណាយមិនឆ្លុះបញ្ចាំងពីស្ថានភាពបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាឡើយ ១

### ផលិតកម្មចិញ្ចឹមជ្រូក ~ ផលិតកូនជ្រូក ~ មួយសំបុក

**ប្រសិទ្ធផលផលិតកម្ម**

| | | |
|---|---|---|
| ការផ្តាច់ដោះជាមធ្យម | 8.3 | *ជ្រូកក្នុង១សំបុក* |
| ការខាត់បង់ដោយជ្រូកងាប់ | 4% | |
| ការខាត់បង់ដោយមេជ្រូកងាប់ | 5% | |
| សំបុកក្នុង១មេជ្រូកក្នុង១ឆ្នាំ | 2.3 | |
| សំបុកក្នុង១ជីវិតមេជ្រូក | 4.0 | |

| **ចំណូល** | **ថ្លៃ** | **ឯកតា** | | **បរិមាណ** | **ឯកតា** | | | | | **Total** |
|---|---|---|---|---|---|---|---|---|---|---|
| ជ្រូកទីផ្សារ | $2.00 | *ក្នុង១គក្រ* | x | 100 | *គក្រ* | *x* | 7.97 | *ក្បាល* | = | $1,593.60 |
| ការលក់មេជ្រូកជ្រើសរើស | $0.70 | *ក្នុង១គក្រ* | x | 200 | *គក្រ* | *x* | 0.25 | *ក្បាល* | = | $35.00 |
| **ចំណូលដុល** | | | | | | | | | | $1,628.60 |

| **ចំណាយប្រែប្រួល** | **ថ្លៃ** | **ឯកតា** | | **បរិមាណ** | **ឯកតា** | | |
|---|---|---|---|---|---|---|---|
| **ចំណាយលើចំណី** | | | | | | | |
| ចំណីផ្សំ | $0.50 | *ក្នុង១គក្រ* | x | 97 | *គក្រ* | = | $48.50 |
| កន្ទក់ | $0.17 | *ក្នុង១គក្រ* | x | 943 | *គក្រ* | = | $160.31 |
| ពោត | $0.06 | *ក្នុង១គក្រ* | x | 267 | *គក្រ* | = | $16.02 |
| គ្រឿងផ្សំចំណីដទៃផ្សេងទៀត | $0.45 | *ក្នុង១គក្រ* | x | 35 | *គក្រ* | = | $15.75 |
| វីតាមីន និងសារធាតុរ៉ែ | $0.30 | *ក្នុង១គក្រ* | x | 95 | *គក្រ* | = | $28.50 |
| វាលស្មៅ | $35.00 | *ក្នុង១ហិត* | x | 0.2 | *ha* | = | $7.00 |
| សារធាតុបន្ថែមលើចំណី | | | | | | | $22.00 |
| ផ្សេងៗ | | | | | | | $0.00 |
| **ចំណាយលើចំណីសរុប** | | | | | | | $298.08 |
| ការព្យាបាល និងសុខភាព | | | | | | | $34.00 |
| ប្រេង ជួសជុល សេវាសាធារណៈ | | | | | | | 35.00 |
| ទ្រុងជ្រូក ទីផ្សារ និងចំណាយបន្ទាប់បន្សំ | | | | | | | 45.00 |
| ផ្សេងៗ | | | | | | | 0.00 |
| ការប្រាក់លើចំណាយប្រែប្រួល | 24% | | x | 0 | *ខែ* | = | 0.00 |
| កម្លាំងពលកម្ម | $0.25 | *ក្នុង១ម៉ោង* | x | 12 | *ម៉ោង* | = | 3.00 |
| **ចំណាយប្រែប្រួលសរុប** | | | | | | | $415.08 |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| **ចំណូលលើចំណាយប្រែប្រួល** | | | | | | | $1,213.52 | |
| **ចំណាយថេរ** | | | | | | | | |
| គ្រឿងចក្រ បរិក្ខារ | | | | | | | $50.00 | |
| ចំណាយលើការបង្កាត់ | | | | | | | 13.00 | |
| បាជ្រូក/ទឹកកាមមេជីវិត | | | | | | | | |
| កូនជ្រូកញីជំនួស | $200.00 | *ក្បាល* | x | 0.26 | *ក្បាល* | = | 52.50 | |
| ការប្រាក់ ធានារ៉ាប់រងលើការបង្កាត់ | 10% | | x | 5.2 | *ខែ* | = | 8.70 | |
| ជ្រូក | | | | | | | | |
| **ចំណាយថេរសរុប** | | | | | | | $124.20 | |
| **សរុបចំណាយទាំងអស់** | | | | | | | $539.28 | |
| **ចំណូលលើចំណាយសរុប** | | | | | | | $1,089.32 | |
| ថ្លៃលក់ស្មើដើមសម្រាប់ចំណាយប្រែប្រួល | | | | | | | $0.48 | *ក្នុង១គឡូ* |
| ថ្លៃលក់ស្មើដើមសម្រាប់ចំណាយទាំងអស់ | | | | | | | $0.63 | *ក្នុង១គឡូ* |

## ផលិតកម្មចិញ្ចឹមជ្រូក ~ ចិញ្ចឹមកូនជ្រូករហូតដល់ធំអាចលក់បាន ~ មួយសំបុក

### ប្រសិទ្ធផលផលិតកម្ម

| | | |
|---|---|---|
| ការផ្តាច់ដោះជាមធ្យម | | *ជ្រូកក្នុង១សំបុក* |
| ការខាតបង់ដោយជ្រូកងាប់ (%) | % | |
| ការខាតបង់ដោយមេជ្រូកងាប់ (%) | % | |
| សំបុកក្នុង១មេជ្រូកក្នុង១ឆ្នាំ | | |
| ក្នុង១ជីវិតមេជ្រូក | | |

### ចំណូល

| | ថ្លៃ | ឯកតា | | បរិមាណ | ឯកតា | | | | | សរុប | |
|---|---|---|---|---|---|---|---|---|---|---|---|
| ជ្រូកទីផ្សារ | $ | *ក្នុង១គក្រ* | x | | *គក្រ* | x | ____ | *ក្បាល* | = | $ | Note 1 |
| ការលក់មេជ្រូកចាស់ | $ | *ក្នុង១គក្រ* | x | | *គក្រ* | x | ____ | *ក្បាល* | = | $ | Note 2 |

**ចំណូលដុល** $

### ចំណាយប្រែប្រួល

| | ថ្លៃ | ឯកតា | | បរិមាណ | ឯកតា | | |
|---|---|---|---|---|---|---|---|
| **ចំណាយលើចំណី** | | | | | | | |
| ចំណីផ្សំ | $ | *ក្នុង១គក្រ* | x | | *គក្រ* | = | $ |
| កន្ទក់ | $ | *ក្នុង១គក្រ* | x | | *គក្រ* | = | $ |
| ពោត | $ | *ក្នុង១គក្រ* | x | | *គក្រ* | = | $ |
| គ្រឿងផ្សំចំណីដទៃផ្សេងទៀត | $ | *ក្នុង១គក្រ* | x | | *គក្រ* | = | $ |
| វីតាមីន និងសារធាតុរ៉ែ | $ | *ក្នុង១គក្រ* | x | | *គក្រ* | = | $ |
| វាលស្មៅ | $ | *ក្នុង១ហត* | x | | *ហត* | = | $ |
| សារធាតុបន្ថែមលើចំណី | | | | | | | $ |
| ផ្សេងៗ | | | | | | | $ |
| **ចំណាយលើចំណីសរុប** | | | | | | | $ |
| ការព្យាបាល និងសុខភាព | | | | | | | $ |
| ប្រេង ជួសជុល សេវាសាធារណៈ | | | | | | | $ |
| ទ្រុងជ្រូក ទីផ្សារ និងចំណាយបន្ទាប់បន្សំ | | | | | | | $ |
| ផ្សេងៗ | | | | | | | $ |
| ការប្រាក់លើចំណាយប្រែប្រួល | % | | x | | *ខែ* | = | $ |
| កម្លាំងពលកម្ម | $ | *ក្នុង១ម៉ោង* | x | | *ម៉ោង* | = | $ |

**ចំណាយប្រែប្រួលសរុប** $

| | | | | | | | |
|---|---|---|---|---|---|---|---|
| **ចំណូលលើចំណាយប្រែប្រួល** | | | | | | $ | |
| **ចំណាយថេរ** | | | | | | | |
| គ្រឿងចក្រ បរិក្ខារ | | | | | | $ | |
| ចំណាយលើការបង្កាត់ជ្រូក | | | | | | $ | |
| បាជ្រូក/ទឹកកាមមេជីវិត | | | | | | | |
| មេជ្រូកជំនួស | $ | *ក្បាល* | x | 0.00 | *ក្បាល* | = $ | Note 3 |
| ការប្រាក់ ធានារ៉ាប់រងលើការបង្កាត់ជ្រូក | % | | x | 0.0 | *ខែ* | = $ | |
| **ចំណាយថេរសរុប** | | | | | | $ | |
| **សរុបចំណាយទាំងអស់** | | | | | | $ | |
| **ចំណូលលើចំណាយសរុប** | | | **ចំណូលដក (-) ចំណាយទាំងអស់** | | | $ | |
| ថ្លៃលក់ស្មើដើមសម្រាប់ចំណាយប្រែប្រួល | | | **ចំណាយប្រែប្រួលសរុបចែក (÷) ចំណូល** | | | $ | *ក្នុង១គក្រ* |
| ថ្លៃលក់ស្មើដើមសម្រាប់ចំណាយទាំងអស់ | | | **សរុបចំណាយទាំងអស់ចែក (÷) ចំណូល** | | | $ | *ក្នុង១គក្រ* |

១ ការលក់សរុប = អត្រាផ្តាច់ដោះមធ្យមដក (-) ការខាតបង់ដោយសារការកូនជ្រូកងាប់ក្នុងកូនជ្រូក១សំបុកដែលបានផ្តាច់ដោះ ។

២ ប៉ានស្មានថា មេជ្រូកចាស់១ក្បាល អស់ផលិតភាព (ដកចេញ) និងលក់ក្នុង៤សំបុក ដោយសារធម្មតា ជីវិតរបស់មេជ្រូកដែលមានប្រយោជន៍ គឺបង្កើតកូនបាន៤សំបុក ។

៣ ចំណាយផ្លាស់ប្តូរមេជ្រូក ជាធម្មតាត្រូវបានគណនា ¼ មេជ្រូកក្នុង១សំបុក ឬ .២៥ ដោយសារមេជ្រូកភាគច្រើនបង្កើតកូនបាន ៤ សំបុកក្នុងមួយជីវិតរបស់ពួកវា ។

**ឧទាហរណ៍ : ចំណាយមិនផ្លុះបញ្ចាំងពីស្ថានភាពបច្ចុប្បន្ននៅក្នុងប្រទេសកម្ពុជាឡើយ ៖**

## ផលិតកម្មចិញ្ចឹមជ្រូក ‑ ផលិតកូនជ្រូកផ្តាច់ដោះទម្ងន់ ១២ គក្រ

**ប្រសិទ្ធផលផលិតកម្ម**

| | |
|---|---|
| ការខាតបង់ដោយមេជ្រូកងាប់ | 5% |
| សំបុកក្នុង១មេជ្រូកក្នុង១ឆ្នាំ | 2.3 |
| សំបុកក្នុង១ជីវិតមេជ្រូក | 4.0 |

| ចំណូល | ថ្លៃ | ឯកតា | | បរិមាណ | ឯកតា | | Total |
|---|---|---|---|---|---|---|---|
| កូនជ្រូកផ្តាច់ដោះ | $50.00 | ក្នុង១ក្បាល | x | 9 | ក្បាល | = | $450.00 |
| ការលក់មេជ្រូកចាស់ | $148.76 | ក្នុង១ក្បាល | x | 0.25 | ក្បា/សំបុក | = | $37.19 |
| **ចំណូលដុល** | | | | | | | $487.19 |

**ចំណាយប្រែប្រួល**

| ចំណាយលើចំណី | ថ្លៃ | ឯកតា | | បរិមាណ | ឯកតា | | |
|---|---|---|---|---|---|---|---|
| ពោត | $4.35 | ក្នុង១គក្រ | x | 17.1 | bu | = | $74.39 |
| អាហារសណ្តែកសៀង | 0.17 | ក្នុង១គក្រ | x | 149 | ផោន | = | 25.33 |
| វីតាមីន និងសារធាតុរ៉ែ | 0.45 | ក្នុង១គក្រ | x | 23 | ផោន | = | 10.35 |
| ការកែច្នៃចំណី និងផ្តល់ចំណី | 10.00 | ក្នុង១គក្រ | x | 0.6 | ក្នុង១គក្រ | = | 6.00 |
| ផ្សេងៗ | | | | | | | 0.00 |
| **ចំណាយលើចំណីសរុប** | | | | | | | $116.07 |
| ការព្យាបាល និងថ្នាំ | | | | | | | $17.00 |
| ប្រេង ជួសជុល សេវាសាធារណៈ | | | | | | | 7.50 |
| ទីផ្សារ និងចំណាយបន្ទាប់បន្សំ | | | | | | | 10.00 |
| ផ្សេងៗ | | | | | | | 0.00 |
| ចំណាយលើជីលាមកសត្វ | $0.00 | សំបុក | x | 1000 | សំបុក | = | 1.00 |
| ការប្រាក់លើចំណាយប្រែប្រួល | 9% | % ឆ្នាំ | x | 3 | ខែ | = | 3.41 |
| កម្លាំងពលកម្មរួមទាំងអត្ថប្រយោជន៍ | $0.25 | ក្នុង១ម៉ោង | x | 3 | ម៉ោង | | 0.75 |
| **ចំណាយប្រែប្រួលសរុប** | | | | | | | $155.73 |
| ការប្រាក់លើចំណាយប្រែប្រួល | | | | | | | $331.46 |

**ចំណាយថេរ**

| | | | | | | | |
|---|---|---|---|---|---|---|---|
| បរិក្ខារ និងសម្ភារៈ | | | | | | | $66.15 |
| ចំណាយលើការបង្កាត់ជ្រូក | | | | | | | 13.00 |
| បាជ្រូក/ទឹកកាមមេជីវិត | | | | | | | |
| មេជ្រូកជំនួស | $155 | *ក្បាល* | x | 0.26 | *ក្បាល* | = | 40.69 |
| ការប្រាក់ ធានារ៉ាប់រងលើមេជ្រូក | 10% | | x | 5.2 | *ខែ* | = | 6.74 |
| **ចំណាយថេរសរុប** | | | | | | | $126.58 |
| **សរុបចំណាយទាំងអស់** | | | | | | | $282.30 |
| **ចំណូលលើចំណាយសរុប** | | **ចំណុលដក (-) ចំណាយទាំងអស់** | | | | | $204.89 |
| ថ្លៃលក់ស្មើដើមសម្រាប់ចំណាយប្រែ ប្រួល | | **ចំណាយប្រែប្រួលសរុបចែក (÷) ចំណូល** | | | | | $13.17 *ក្នុង១ក្បាល* |
| ថ្លៃលក់ស្មើដើមសម្រាប់ចំណាយទាំងអស់ | | **សរុបចំណាយទាំងអស់ចែក (÷) ចំណូល** | | | | | $27.23 *ក្នុងក្បាល* |

# ផលិតកម្មចិញ្ចឹមជ្រូក ~ ផលិតកូនជ្រូកផ្តាច់ដោះទម្ងន់ ១២ គក្រ

**ប្រសិទ្ធផលផលិតកម្ម**

| | |
|---|---|
| ការខាត់បង់ដោយមេជ្រូកងាប់ (%) | % |
| សំបុកក្នុង១មេជ្រូកក្នុង១ឆ្នាំ | |
| សំបុកក្នុង១ជីវិតមេជ្រូក | |

| **ចំណូល** | **ថ្លៃ** | **ឯកតា** | | **បរិមាណ** | **ឯកតា** | | **សរុប** | |
|---|---|---|---|---|---|---|---|---|
| កូនជ្រូកផ្តាច់ដោះ | $ | *ក្នុង១ក្បាល* | x | | *ក្បាល* | = | $ | |
| ការលក់មេជ្រូកចាស់ | | | x | | *ក្ប/* | = | $ | Note 1 |
| | $ | *ក្នុង១ក្បាល* | | | សំបុក | | | |
| **ចំណូលដុល** | | | | | | | $ | |

**ចំណាយប្រែប្រួល**

| **ចំណាយលើចំណី** | **ថ្លៃ** | **ឯកតា** | | **បរិមាណ** | **ឯកតា** | | |
|---|---|---|---|---|---|---|---|
| ពោត | $ | *ក្នុង១គក្រ* | x | | *bu* | = | $ |
| អាហារសណ្តែកសៀង | $ | *ក្នុង១គក្រ* | x | | *ផោន* | = | $ |
| វីតាមីន និងសារធាតុរ៉ែ | $ | *ក្នុង១គក្រ* | x | | *ផោន* | = | $ |
| ការកែច្នៃចំណី និងផ្តល់ចំណី | $ | *ក្នុង១គក្រ* | x | | *ក្នុង១គក្រ* | = | $ |
| ផ្សេងៗ | | | | | | | $ |
| **ចំណាយលើចំណីសរុប** | | | | | | | $ |
| ការព្យបាល និងថ្នាំ | | | | | | | $ |
| ប្រេង ជួសជុល សេវាសាធារណៈ | | | | | | | $ |
| ទីផ្សារ និងចំណាយបន្ទាប់បន្សំ | | | | | | | $ |
| ផ្សេងៗ | | | | | | | $ |
| ចំណាយលើជីលាមកសត្វ | $ | សំបុក | x | | *សំបុក* | = | $ |
| ការប្រាក់លើចំណាយប្រែប្រួល | % | *% ឆ្នាំ* | x | | *ខែ* | = | $ |
| កម្លាំងពលកម្មរួមទាំងអត្ថប្រយោជន៍ | $ | *ក្នុង១ម៉ោង* | x | | *ម៉ោង* | | $ |
| | | | | | | | $ |
| **ចំណាយប្រែប្រួលសរុប** | | | | | | | $ |
| ការប្រាក់លើចំណាយប្រែប្រួល | | | | | | | $ |

**ចំណាយថេរ**

| | |
|---|---|
| បរិក្ខារ និងសម្ភារៈ | $ |

| | | | | | | | | |
|---|---|---|---|---|---|---|---|---|
| ចំណាយលើការបង្កាត់ | | | | | | | $ | |
| បាជ្រូក/ទឹកកាមមេជីវិត | | | | | | | | |
| មេជ្រូកជំនួស | $ | *ក្បាល* | x | 0.00 | *ក្បាល* | = | $ | Note 2 |
| ការប្រាក់ ធានារ៉ាប់រងលើមេជ្រូក | $ | | x | 0.0 | *ខែ* | = | $ | |
| | | | | | | | $ | |
| **ចំណាយថេរសរុប** | | | | | | | $ | |
| **សរុបចំណាយទាំងអស់** | | | | | | | $ | |
| **ចំណូលលើចំណាយសរុប** | | | **ចំណូលដក (-) ចំណាយទាំងអស់** | | | | $ | |
| ថ្លៃលក់ស្មើដើមសម្រាប់ចំណាយប្រែប្រួល | | | **ចំណាយប្រែប្រួលសរុបចែក (÷) ចំណូល** | | | | $ | *ក្នុង១ក្បាល* |
| ថ្លៃលក់ស្មើដើមសម្រាប់ចំណាយទាំងអស់ | | | **សរុបចំណាយទាំងអស់ចែក (÷) ចំណូល** | | | | $ | *ក្នុង១ក្បាល* |

១ ប៉ាន់ស្មានថា មេជ្រូកចាស់១ក្បាល អស់ផលិតភាព (ដកចេញ) និងលក់ក្នុង ៤ សំបុក ដោយសារធម្មតា ជីវិតរបស់មេជ្រូកដែលមានប្រយោជន៍គឺបង្កើតកូនបាន ៤ សំបុក ។

២ មេជ្រូកជំនួសត្រូវបានគណនានឹង ១ ក្នុង ៤ សំបុក ។ រូបមន្ត : (១ + ការខាតបង់ដោយមេជ្រូកងាប់ %) ចែកនឹង (÷) (សំបុកក្នុង១ជីវិតមេជ្រូក)

## ឧបករណ៍ទី ២ : បញ្ជីផ្ទៀងផ្ទាត់ ការគ្រប់គ្រងហានិភ័យសម្រាប់ធ្វើការវាយតម្លៃអ្នកចិញ្ចឹមជ្រូក

បញ្ជីផ្ទៀងផ្ទាត់ដែលបានបង្ហាញនៅក្នុងផ្នែកនេះ ផ្តល់អោយមន្ត្រីឥណទាន និងអ្នកវិជ្ជាជីវៈហិរញ្ញវត្ថុដទៃផ្សេងទៀតនូវមធ្យោបាយឆាប់រហ័សមួយសម្រាប់ធ្វើការវាយតម្លៃជំនាញ និងវិជ្ជាជីវៈរបស់អ្នកចិញ្ចឹមជ្រូក ពាក់ព័ន្ធនឹងផលិតកម្ម ដំណើរការកសិដ្ឋាន សុខភាពសត្វ ត្រួតពិនិត្យចំណាយ និងទីផ្សារ ។

ប្រព័ន្ធដាក់ពិន្ទុដែលបានគូសបញ្ជាក់នៅក្នុងទំព័រទាំងនេះ ជាមធ្យោបាយសាមញ្ញមួយដើម្បីវាយតម្លៃចំណុចនានាសម្រាប់ប្រភេទនីមួយៗនៃប្រភេទទាំងនេះ ដោយផ្អែកលើទម្លាប់អនុវត្តន៍របស់អ្នកចិញ្ចឹមជ្រូកដែលត្រូវបានអង្កេត ឬរាយការណ៍ ។

គម្រោង MSME នេះ លើកទឹកចិត្តអោយអ្នកធ្វើការថតចម្លងដោយសេរី និងប្រើឧបករណ៍ទាំងនេះជាការលើកទឹកចិត្តដល់ការគ្រប់គ្រងហានិភ័យជាក់លាក់ និងនីតិវិធីវាយតម្លៃអតិថិជនរបស់ស្ថាប័នអ្នក ។

**ការចិញ្ចឹមជ្រូក**

ការទិញកូនជ្រូកសម្រាប់ចិញ្ចឹម និងលក់ជ្រូកទាំងនោះទៅអោយឈ្មួញ ឬកន្លែងសត្តឃាត ក្នុងទម្ងន់ប្រហែល ១០០ គក្រ

| | **ចំណុចវាយតម្លៃ** | **ចំណុចដែលអាចមាន** | **គ្មានពិន្ទុ** |
|---|---|---|---|
| | **ការវាស់វែងលទ្ធផលការងារ** | | |
| | រយៈពេលពីពេលទិញរហូតដល់ពេលលក់ < ១៥០ ថ្ងៃ | ៥ | |
| | ទម្ងន់នៅពេលលក់ជ្រូកសម្រេច : ៩០-១០០ គក្រ | ៤ | |
| | ទម្ងន់កើនក្នុង១ថ្ងៃ ពី ៦០០-៧០០ ក្រាម | ៧ | |
| | អត្រាស្លាប់នៃជ្រូកចិញ្ចឹម < ៣% | ៤ | |
| | **សរុបប្រភេទ** | **២០** | |
| | **ដំណើរការកសិដ្ឋាន** | | |
| | ជ្រូកទាំងអស់ដែលរក្សានៅក្នុងទ្រុងតែមួយមានអាយុស្មើគ្នា ( ទំហំ) | ២ | |
| | ទំហំអប្បបរមានៃទ្រុងជ្រូកសម្រាប់ជ្រូកមួយ គឺ ១ម២ | ៦ | |
| | ចំនួនជ្រូកចិញ្ចឹមអតិបរមាក្នុងមួយទ្រុង | ៣ | |
| | សំអាតទ្រុងជ្រូកម្តងក្នុង ១ ថ្ងៃ | ៥ | |
| | សំលាប់មេរោគទ្រុងជ្រូក ៣ ក្នុង ១ ថ្ងៃ | ៤ | |
| | **សរុបប្រភេទ** | **២០** | |
| | **សុខភាពសត្វ** | | |
| | អ្នកចិញ្ចឹមត្រូវដឹងពីប្រភពរបស់កូនជ្រូក | ២ | |
| | ទ្រុងជ្រូកត្រូវធ្វើអោយឆ្ងាយពីផ្លូវ ហើយការចូលទៅកាន់ទ្រុងជ្រូកត្រូវត្រួតពិនិត្យ | ២ | |
| | ញែកចំណី ទឹក និងកាកសំណល់នៅក្នុងទ្រុងជ្រូកពីគ្នា | ៣ | |
| | ទ្រុងជ្រូកត្រូវស្ងួត លើកលែងតែកន្លែងដាក់កាកសំណល់ | ៣ | |
| | ជ្រូកចិញ្ចឹមត្រូវចាប់វ៉ាក់សាំងមុនពេលទិញ | ៤ | |
| | ត្រូវផ្តល់ទឹកស្អាតអោយជ្រូកផឹកគ្រប់ពេល | ២ | |
| | អ្នកចិញ្ចឹមត្រូវព្យាបាលជំងឺជ្រូកភ្លាមៗ | ៤ | |
| | **សរុបប្រភេទ** | **២០** | |
| | **ការត្រួតពិនិត្យ និងគ្រប់គ្រងចំណាយ** | | |
| | អ្នកចិញ្ចឹមត្រូវរក្សាកំណត់ត្រាចំណាយមូលដ្ឋាន | ២ | |
| | អ្នកចិញ្ចឹមត្រូវរក្សាកំណត់ត្រាកាលបរិច្ឆេទការទិញ និងលក់ជ្រូក | ៤ | |

| | | | |
|---|---|---|---|
| | និងទម្ងន់ផងដែរ | | |
| | អ្នកចិញ្ចឹមត្រូវរក្សាកំណត់ត្រាទិញគ្រឿងផ្សំចំណីជ្រូក | ៣ | |
| | អ្នកចិញ្ចឹមត្រូវរក្សាកំណត់ត្រានៃកាលបរិច្ឆេទចាក់វ៉ាក់សាំង | ៥ | |
| | លទ្ធភាពទទួលបានចំណីជ្រូក (គ្រឿងផ្សំដើម) : នៅក្នុងកសិដ្ឋាន ក្នុងគ្រួសារ ឬកន្លែងក្នុងមូលដ្ឋានដទៃផ្សេងទៀត | ៤ | |
| | ចំណីដែលបានទិញត្រូវបានលាយជាមួយនឹងគ្រឿងផ្សំដើម ដូចជា ពោត កន្ទក់ អង្កាម ឬកន្ទក់ស្រូវសាឡីដើម្បីគ្រប់គ្រងចំណាយលើចំណី | ២ | |
| | **សរុបប្រភេទ** | ២០ | |
| | **បញ្ហាទីផ្សារ** | | |
| | អ្នកចិញ្ចឹមត្រូវផលិតជ្រូកជាច្រើនវគ្គសម្រាប់លក់នៅក្នុងពេលខុសៗគ្នា ជាជាងលក់ទាំងអស់ក្នុងពេលតែមួយ ដើម្បីកាត់បន្ថយហានិភ័យផ្នែកទីផ្សារ | ៥ | |
| | អ្នកចិញ្ចឹមត្រូវប្រើពូជជ្រូកដែលល្អជាមុន ឬ "ហៃ្សនខ្ពស់" | ៦ | |
| | អ្នកចិញ្ចឹមត្រូវស្គាល់អតិថិជនអោយបានច្រើនលើសពីម្នាក់សម្រាប់ជ្រូកធំ ដែលអាចលក់អោយទីផ្សារបាន | ៥ | |
| | អ្នកចិញ្ចឹមត្រូវដឹងពីតម្រូវការនៃទីផ្សារចុងក្រោយ និងត្រូវមានបណ្តាញទីផ្សារសមស្រមដើម្បីទៅដល់ទីផ្សារទាំងនេះ | ៤ | |
| | **សរុបប្រភេទ** | **២០** | |
| | **សរុបសម្រាប់ប្រភេទទាំងអស់** | **១០០** | |

## ការផលិតកូនជ្រូក

អ្នកចិញ្ចឹមត្រូវរក្សាមេជ្រូកអោយបង្កើតកូនជ្រូកសម្រាប់លក់ទៅអោយអ្នកចិញ្ចឹមជ្រូកដទៃផ្សេងទៀត ។ បាជ្រូកត្រូវរក្សាទុក ឬ "ជួល" សម្រាប់ពាក់មេជ្រូក ។

| | ចំណុចវាយតម្លៃ | ចំណុចដែលអាចមាន | គ្មានពិន្ទុ |
|---|---|---|---|
| | **ការវាស់វែងលទ្ធផលការងារ និងភាពអាចចំណេញបាន** | | |
| | ទំហំសំបុកជ្រូកគឺ ១១ ក្បាល/សំបុក | ២,៥ | |
| | មេជ្រូកត្រូវការបា ២,២ ដង/ឆ្នាំ | ២,៥ | |
| | មេជ្រូកត្រូវការបា ៧ ថ្ងៃ បន្ទាប់ពីផ្តាច់ដោះ | ២,៥ | |
| | អត្រាស្លាប់របស់កូនជ្រូកមុនពេលផ្តាច់ដោះ < ១២% | ២,៥ | |
| | កូនជ្រូកផ្តាច់ដោះនៅអាយុ ២៨ ថ្ងៃ | ២,៥ | |
| | កូនជ្រូកផ្តាច់ដោះនៅទម្ងន់ ៧,៥-៨ គក្រ | ២,៥ | |
| | កូនជ្រូកលក់ក្នុងទម្ងន់ ១២-១៥ គក្រ | ២ | |
| | កូនជ្រូកលក់នៅអាយុពី ៥-៦ សប្តាហ៍ | ១ | |
| | អ្នកចិញ្ចឹមជ្រូកប្រើទឹកកាមសិប្បនិម្មិត | ២ | |
| | **សរុបប្រភេទ** | **២០** | |
| | **ដំណើរការកសិដ្ឋាន** | | |
| | កូនជ្រូក ១០ ក្បាល ត្រូវមានទុយោផឹកទឹក ១ | ៦ | |
| | ទុយោផឹកទឹកត្រូវមានប្រវែង ១០ សម ពីដី | ៤ | |
| | ទ្រុងជ្រូកត្រូវមានទំហំ ១ម$^{២}$ សម្រាប់កូនជ្រូកពី ៣-៤ ក្បាល | ៧ | |
| | ចំនួនកូនជ្រូកអតិបរមា ១២ ក្បាល ក្នុង ១ ទ្រុង (១ សំបុក) | ៣ | |
| | **សរុបប្រភេទ** | **២០** | |
| | **សុខភាពសត្វ** | | |
| | អ្នកចិញ្ចឹមត្រូវដឹងពីប្រភពរបស់កូនជ្រូក | ២ | |
| | ទ្រុងជ្រូកត្រូវធ្វើអោយឆ្ងាយពីផ្លូវ ហើយការចូលទៅកាន់ទ្រុងជ្រូកត្រូវត្រួតពិនិត្យ | ២ | |
| | ញែកចំណី ទឹក និងកាកសំណល់នៅក្នុងទ្រុងជ្រូកពីគ្នា | ២ | |
| | ទ្រុងជ្រូកត្រូវស្ងួត លើកលែងតែកន្លែងដាក់កាកសំណល់ | ៣ | |
| | អ្នកចិញ្ចឹមត្រូវព្យាបាលជំងឺជ្រូកភ្លាមៗ | ៣ | |
| | ចង្កៀងកម្តៅសម្រាប់កូនជ្រូកមុនពេលផ្តាច់ដោះ | ៣ | |
| | ការចាក់វ៉ាក់សាំង និងការព្យាបាលប្រឆាំងប៉ារ៉ាសិត (៤) កូនជ្រូកមុនពេលលក់ | ៣ | |

| | | | |
|---|---|---|---|
| | ការចាក់វ៉ាក់សាំង និងការព្យាបាលប្រឆាំងប៉ារ៉ាសិត មេជ្រូកពេលកំពុងមានផ្ទៃពោះ (៤) និងនៅពេលកើតកូន (១) | ៣ | |
| | ត្រូវផ្តល់ទឹកស្អាតអោយជ្រូកផឹកគ្រប់ពេល | ២ | |
| | **សរុបប្រភេទ** | **២០** | |
| | **ការត្រួតពិនិត្យ និងគ្រប់គ្រងចំណាយ** | | |
| | អ្នកចិញ្ចឹមជ្រូកត្រូវរក្សាកំណត់ត្រាចំណាយមូលដ្ឋាន | ២ | |
| | អ្នកចិញ្ចឹមជ្រូកត្រូវរក្សាកំណត់ត្រានៃកាលបរិច្ឆេទផ្តាច់ដោះ | ៤ | |
| | អ្នកចិញ្ចឹមជ្រូកត្រូវរក្សាកំណត់ត្រាកើតកូនជ្រូក | ៤ | |
| | អ្នកចិញ្ចឹមជ្រូកត្រូវរក្សាកំណត់ត្រាទំហំសំបុកកូនជ្រូក និងចំនួននៅរស់ | ៣ | |
| | អ្នកចិញ្ចឹមជ្រូកត្រូវរក្សាកំណត់ត្រាកាលបរិច្ឆេទចាក់វ៉ាក់សាំង | ៥ | |
| | ចំណីដែលបានទិញត្រូវបានលាយជាមួយនឹងគ្រឿងផ្សំដើម ដូចជា ពោត កន្ទក់ អង្កាម ឬសន្ទក់ស្រូវសាឡីដើម្បីគ្រប់គ្រងចំណាយលើចំណី | ២ | |
| | **សរុបប្រភេទ** | **២០** | |
| | **បញ្ហាទីផ្សារ** | | |
| | អ្នកចិញ្ចឹមត្រូវប្រើពូជជ្រូកដែលមានហ្សែនល្អជាងមុន | ៨ | |
| | អ្នកចិញ្ចឹមត្រូវមានកេរ្តិ៍ឈ្មោះល្អសម្រាប់ការរស់របស់ជ្រូកក្នុងចំណោមអតិថិជន | ៦ | |
| | អ្នកចិញ្ចឹមត្រូវមានអតិថិជនច្រើនសម្រាប់កូនជ្រូក | ៦ | |
| | **សរុបប្រភេទ** | **២០** | |
| | **សរុបសម្រាប់ប្រភេទទាំងអស់** | **១០០** | |

**ប្រតិបត្តិការបង្កើតកូនជ្រូករហូតដល់ជ្រូកធំអាចលក់បាន**

អ្នកចិញ្ចឹមត្រូវរក្សាមេជ្រូកអោយកើតបានកូនជ្រូកដើម្បីចិញ្ចឹម និងលក់ទៅអោយឈ្មួញ ឬកន្លែងសត្តឃាត ក្នុងទម្ងន់ប្រហែល ១០០ គក្រ ។

អ្នកដែលមានលទ្ធភាពគប្បីគួរតែប្រើគំរូទាំងពីរខាងលើ គំរូមួយសម្រាប់សមាសភាពបង្កើតកូនជ្រូក និងគំរូមួយទៀតសម្រាប់សមាសភាពចិញ្ចឹមជ្រូកនៃអាជីវកម្មរបស់អ្នកចិញ្ចឹម ។

## ឧបករណ៍ទី ៣ : ទម្រង់កត់ត្រាបញ្ជីសមស្របសម្រាប់អ្នកចិញ្ចឹមជ្រូក

ទម្រង់កត់ត្រាបញ្ជីដែលមាននៅក្នុងឧបករណ៍ទី ៣ នេះ ផ្តល់នូវទម្រង់មូលដ្ឋានមួយសម្រាប់អ្នកចិញ្ចឹមជ្រូកដើម្បីកត់ត្រាចំណាយ និងចំណូល ( ការលក់) របស់ពួកគេក្នុងមួយខែៗ ។

គម្រោង MSME កម្ពុជា និងស្ថាប័នហិរញ្ញវត្ថុកម្ពុជាមានបំណងរួមគ្នាដើម្បីជួយអ្នកចិញ្ចឹមជ្រូក MSME អោយក្លាយជាអ្នកជំនួញដែលល្អជាងនេះ ។ ជាលទ្ធផល យើងបានរៀបចំទំព័រកត់ត្រាបញ្ជីប្រចាំខែដ៏សាមញ្ញមួយ ដែលនឹងរក្សាចំណាយពាក់ព័ន្ធចម្បងៗសម្រាប់អាជីវកម្មចិញ្ចឹមជ្រូក នៅក្នុងទម្រង់មួយដែលមានលក្ខណៈសាមញ្ញបំផុត សម្រាប់ប្រព័ន្ធគណនីសាច់ប្រាក់ ។

ប្រសិនបើអ្នកមានបំណងចង់លើកទឹកចិត្តដល់អតិថិជនដែលជាអ្នកចិញ្ចឹមជ្រូក អោយកត់ត្រាបញ្ជីល្អជាងមុន ដើម្បីមានលទ្ធភាពទទួលបានការផ្តល់ឥណទាន និងកម្ចី អ្នកអាចផ្តល់នូវសំណៅចម្លងនៃទម្រង់បញ្ជីសមស្រប ( សម្រាប់អ្នកចិញ្ចឹមកូនជ្រូករហូតដល់ធំអាចលក់បាន ឬការផលិតកូនជ្រូក)

គំរូបញ្ជីទាំងនេះមិនតម្រូវចាំបាច់អោយមានជំនាញអាជីវកម្មខ្ពស់ដើម្បីបំពេញឡើយ ។ គំរូកំណត់ត្រាទាំងនេះគ្រាន់តែតម្រូវអោយមានភាពស៊ីសង្វាក់គ្នាដែលមានសារសំខាន់បំផុតសម្រាប់តាមដានចំណាយអាជីវកម្ម និងការលក់ ។

អ្នកអាចណែនាំអ្នកចិញ្ចឹមជ្រូកអោយសរសេរកាលបរិច្ឆេទ និងពាក្យមួយចំនួនដែលពិពណ៌នាអំពីចំណាយនីមួយៗ និងបន្ទាប់មក អោយសរសេរចំនួនទឹកប្រាក់ដែលពួកគេបានចំណាយនៅពីក្រោមរូបភាពអោយត្រឹមត្រូវនឹងប្រភេទចំណាយ ។ ជាងនេះទៅទៀតត្រូវណែនាំអ្នកចិញ្ចឹមជ្រូកអោយប្រើក្រដាសផ្សេងសម្រាប់ខែនីមួយៗនៃឆ្នាំ ។

ឧទាហរណ៍ :

អ្នកចិញ្ចឹមជ្រូកម្នាក់ដែលបានទិញកូនជ្រូក ៥ ក្បាល នៅថ្ងៃទី១៩ ខែមករា តម្លៃ ៣០០ ដុល្លារ ត្រូវកត់ត្រា :
"ថ្ងៃទី១៩ ខែមករា កូនជ្រូក ៥ ក្បាល មួយទម្ងន់ ១២ គក្រ" "៣០០ ដុល្លារ" នៅក្នុងកូឡោន ទិញសត្វ

អ្នកចិញ្ចឹមជ្រូកម្នាក់ដែលបានទិញចំណីម៉ាក់ Medivet ៣០ គក្រ នៅថ្ងៃទី០១ ខែកុម្ភៈ តម្លៃ ៥០ ដុល្លារ ត្រូវសរសេរ :
"ថ្ងៃទី០១ ខែកុម្ភៈ ៣០ គក្រ ចំណីម៉ាក់ Medivet" និងសរសេរ ៥០ ដុល្លារ នៅកូឡោនដែលមានរូបភាពកញ្ចប់ចំណីសត្វ ។

នៅដំណាច់ខែ ងាយស្រួលក្នុងការគណនាចំណាយសរុបសម្រាប់ប្រភេទនីមួយៗ ដោយការបន្ថែមកូឡោន ។

ប្រសិនបើអ្នកចិញ្ចឹមជ្រូកកត់ត្រាបញ្ជីទាំងនេះដោយស៊ីសង្វាក់គ្នានោះ អ្នកអាចទទួលរបាយការណ៍លំហូរសាច់ប្រាក់លម្អិតពីបញ្ជីទាំងនេះនៅដំណាច់ឆ្នាំ ដើម្បីជួយដល់ការវាយតម្លៃកម្ចីរបស់អ្នកដំណើរការ ។

របាយការណ៏សង្ខេបប្រចាំឆ្នាំ (ទម្រង់ ២ ចុងក្រោយ) អាចបំពេញដោយកត់ត្រាលំហូរសាច់ប្រាក់ទូទៅរបស់អាជីវកម្មពេញមួយឆ្នាំ និងជួយអោយអតិថិជនរបស់អ្នកបានយល់អំពីវដ្តអាជីវកម្មផងដែរ ។

មិនមានអ្នកចិញ្ចឹមជ្រូកទាំងអស់សុទ្ធតែមានឆន្ទៈគ្រប់គ្រាន់ក្នុងការបំពេញបញ្ជីទាំងនេះនោះទេ ប៉ុន្តែការលើកទឹកចិត្តរបស់អ្នកអាចជួយអោយអ្នកទាំងនោះ មានទឹកចិត្តក្នុងការអនុវត្តតាម និងបន្តដើម្បីធ្វើអោយដំណើរការអាជីវកម្មចិញ្ចឹមជ្រូករបស់ពួកគេមានលក្ខណៈវិជ្ជាជីវៈ ។

កំណត់ត្រាចំណាយសម្រាប់ដំណើរការចិញ្ចឹមជ្រូក ខែ ____________ ឆ្នាំ២០__

| | | ថ្លៃដើម និងចំណាយ | | | | | | លក់ |
|---|---|---|---|---|---|---|---|---|
| | | ទិញសត្វ | ចំណី | ថ្នាំ និងវ៉ាក់សាំង | ឧបករណ៍ ឬ សម្ភារៈ | កម្លាំងពលកម្ម | ទ្រុងជ្រូក និងការជួសជុល | |
| **កាលបរិច្ឆេទ** | **បរិយាយ** |  |  |  |  |  |  |  |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | | | | | | | | |
| | សរុបប្រចាំខែ | | | | | | | |

របាយការណសង្ខេបលំហូរសាច់ប្រាក់ប្រចាំឆាំសម្រាប់ការចិញ្ចឹមជ្រូក ឬដំណើរការបង្កើតកូនជ្រូករហូតដល់ជ្រូកធំអាចលក់បាន ឆ្នាំ២០______________

| | | ថ្លៃដើម និងចំណាយ | | | | | | | **លក់** |
|---|---|---|---|---|---|---|---|---|---|
| | | ទិញសត្វ | ចំណាយ បង្កកំណើត | ចំណី | ថ្នាំ និង វ៉ាក់សាំង | ឧបករណ៍ ឬ សម្ភារៈ | កម្លាំងពលកម្ម | ទ្រុងជ្រូក និង ការជួសជុល | |
| **កាលបរិច្ឆេទ** | **បរិយាយ** |  |  |  |  |  |  |  |  |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | | | | | | | | | |
| | សរុបប្រចាំខែ | | | | | | | | |

របាយការណ៍សង្ខេបលំហូរសាច់ប្រាក់ប្រចាំឆ្នាំសម្រាប់ការចិញ្ចឹមជ្រូក ឬដំណើរការបង្កើតកូនជ្រូករហូតដល់ជ្រូកធំអាចលក់បាន ឆ្នាំ២០____________

| | ថ្លៃដើម និងចំណាយ | | | | | | | ការលក់ |
|---|---|---|---|---|---|---|---|---|
| | ទិញសត្វ | ចំណី | ថ្នាំ និងវ៉ាក់សាំង | ឧបករណ៍ ឬ សម្ភារៈ | កម្លាំងពលកម្ម | ទ្រុងជ្រូក និងការជួសជុល | សរុបចំណាយ | |
| **ខែ** |  |  |  |  |  |  | $/RL |  |
| មករា | | | | | | | | |
| កុម្ភៈ | | | | | | | | |
| មីនា | | | | | | | | |
| មេសា | | | | | | | | |
| ឧសភា | | | | | | | | |
| មិថុនា | | | | | | | | |
| កក្កដា | | | | | | | | |
| សីហា | | | | | | | | |
| កញ្ញា | | | | | | | | |
| តុលា | | | | | | | | |
| វិច្ឆិកា | | | | | | | | |
| ធ្នូ | | | | | | | | |
| **សរុប** | | | | | | | | |

របាយការណ៍សង្ខេបលំហូរសាច់ប្រាក់ប្រចាំឆ្នាំសម្រាប់ការចិញ្ចឹមជ្រូក ឬដំណើរការបង្កើតកូនជ្រូករហូតដល់ជ្រូកធំអាចលក់បាន ឆ្នាំ២០______________

| | ថ្លៃដើម និងចំណាយ | | | | | | | | **ការលក់** |
|---|---|---|---|---|---|---|---|---|---|
| | ទិញសត្វ | ចំណាយបង្កាត់ - បាជ្រូក | ចំណី | ថ្នាំ និង វ៉ាក់សាំង | ឧបករណ៍ ឬ សម្ភារៈ | កម្លាំងពលកម្ម | ទ្រុងជ្រូក និង ការជួសជុល | សរុបចំណាយ | |
| **ខែ** |  |  |  |  |  |  |  | $/RL |  |
| មករា | | | | | | | | | |
| កុម្ភៈ | | | | | | | | | |
| មីនា | | | | | | | | | |
| មេសា | | | | | | | | | |
| ឧសភា | | | | | | | | | |
| មិថុនា | | | | | | | | | |
| កក្កដា | | | | | | | | | |
| សីហា | | | | | | | | | |
| កញ្ញា | | | | | | | | | |
| តុលា | | | | | | | | | |
| វិច្ឆិកា | | | | | | | | | |
| ធ្នូ | | | | | | | | | |
| **សរុប** | | | | | | | | | |